# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ខៀវ នៅ ភេទប្រុស អាយុ៨០ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ "ប្រធានសេដ្ឋកិច្ចភូមិភាគនិរតី"**

**ស្រុកកំណើតៈ ភូមិត្រពាំងគល់ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ**

**សព្វថ្ងៃរស់នៅភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:៥១:៥៩**

**៤១ទំព័រ**

ដានីៈ លោកតាមុននឹងចាប់ផ្ដើមខ្ញុំចង់ណែនាំខ្លួនប្រាប់លោកតាមួយសារទៀត ខ្ញុំឈ្មោះ ដានី ហើយគាត់ឈ្មោះ បូលី ពីរនាក់ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគោលបំណង ដែលពួកខ្ញុំចុះមកជួបលោកតា គឺក្នុងគម្រោងដើម្បីចងក្រងនិងសរសេរពីសៀវភៅមគ្គុទេស ទេសចរណ៍នៅតំបន់អន្លង់វែងនេះ ។

នៅៈ ឥឡូវសួរបកបន្តិចវិញ កំរិតវប្បធម៌ ។

ដានីៈ កំរិតវប្បធម៌យ៉ាងម៉េចលោកតា?

នៅៈ ថ្នាក់រៀន រៀនដល់ណា?

ដានីៈ លោកតាខ្ញុំរៀនចប់អនុបណ្ឌិតមកពីប្រទេសអង់គ្លេស ហើយបូលីកំពុងរៀនថ្នាក់បណ្ឌិតនៅ សហរដ្ឋអាមេរិក ។

បូលីៈ កូនសិស្ស ។

ដានីៈ កូនសិស្ស បូលីនៅរៀនថ្នាក់បណ្ឌិត ហើយខ្ញុំរៀនចប់ហើយ ។

នៅៈ ប៉ុន្តែអត់ទាន់បានអនុបណ្ឌិតនៅស្រុកខ្មែរទេ?

បូលីៈ អត់មានផង ។

នៅៈ ឥឡូវនិយាយលេងបន្តិច កុំអាលយកជាផ្លូវការ និយាយលេងរឿងពីដើម ពីដើមច្រើន សញ្ញាប័ត្រមកពីស្រុកក្រៅ ។

បូលីៈ អត់ដឹងប្រវត្តិពីដើមមកផង ។

នៅៈ យើងមិនមែនអ្នកប្រវត្តិសាស្ត្រអីមែនទែនទេ គ្រាន់តែប្រហែល និយាយគៗគ្នា មានអី រៀនដល់អ៊ឺរ៉ុប ធាតុអាកាសម៉ាស៊ីនត្រជាក់សព្វបែបយ៉ាង មកធ្វើការស្រុកខ្មែរមាននេះណា

សម័យបង១ ចេះ១ សូត្រតែទ្រឹស្ដីចេញពីសាលា សូត្រហើយសម័យគាទ្រឹស្ដីវាអីចឹង និយាយពីធ្វើ១ យ៉ាងម៉េច វាទាមទារតែប៉ុណ្ណឹង ។

បូលីៈ ធ្វើអត់កើត ។

នៅៈ ហ្នឹងអីចឹង ធ្វើ១ យ៉ាងម៉េច ។

បូលីៈ គាធ្លាប់ទៅរៀននៅបារាំងដែរ បានដឹង?

នៅៈ ខ្ញុំអ្នកបួសទេ គ្មានបានទៅណាឆ្ងាយទេ ទៅនៅតែភ្នំពេញ តែយើងចេះតែលឺ១ យើងជិត ៨០ ហើយ ។

បូលីៈ បួសវត្តណា?

នៅៈ នៅខាងតាកែវ ស្នាក់រៀននៅភ្នំពេញនៅវត្តមហាមន្ត្រី តែពេល៥៤-៥៥ បារាំងចេញ បាត់ទៅអាហ្នឹងឯករាជ្យហើយប្រកាស យើងស្ដាប់ទៅតាមវិទ្យុ កាលហ្នឹងអត់មានទូរទស្សន៍ មានប៉ុស្តិ៍វិទ្យុដែរ ស្ដាប់តាមវិទ្យុ វិទ្យុហ្នឹងមួយវត្តមហាមន្ត្រីហ្នឹងមានកន្លែងលោក គ្មានបាន មានច្រើនទេ មានតិចតួចទេ ។

ដានីៈ លោកតាខ្ញុំចង់ដឹងប្រវត្តិអីចឹងដែរ លោកតាខ្ញុំចង់សួរលោកតាបណ្ដោយ ចង់សួរពីប្រវត្តិ រឿងរ៉ាវដើមអីចឹង ។ អីចឹងលោកអនុញ្ញាតឲ្យពួកខ្ញុំសួរនាំតែម្ដងទៅលោកតា ម៉េចដែរ?

នៅៈ ឥឡូវយើងនិយាយព្រាងសិន កុំអាល(ស្ដាប់មិនបាន) យើងព្រាងមើលសិន និយាយអត់ បានគិត ចេះតែថតយកទៅ ដល់នេះយកទៅមានរឿងអីណាផ្សេង យកជារឿងមែនទែន ដែលខ្ញុំនិយាយអត់គុង អត់ព្រាង អីចឹងចូលតែម្ដង អីចឹងបានថាចង់ព្រាង ប្រវត្តិសាស្ត្រ យើងអត់មានធ្វើលេងទេ នេះសញ្ញាប័ត្រប្រវត្តិសាស្ត្រ?

ដានីៈ ខ្ញុំសញ្ញាប័ត្រខាងសន្តិភាព ហើយនិងផ្សះផ្សារជាតិ ។

នៅៈ ក្រោមអាណានិគមគេមក ដើរតែតាមគេអត់មាន ជួយប្រជាជន ។

បូលីៈ បារាំងក៏អីចឹងដែរ ។

ដានីៈ បារាំងក៏អីចឹងដែរ ។

នៅៈ ឥឡូវយើងនិយាយលេង ខ្ញុំច្រើននិយាយលេងក្រៅប្រវត្តិសាស្ត្រ បារាំង អង់គ្លេសអ្នក លេងដើងចាស់ បារាំងនិងចិន ខ្មែរខ្វួនលាវ នៅក្នុងអាណានិគមបារាំងវា២០ឆ្នាំ ដល់ អាយុ២០ បានសន្ធិសិទ្ធសីណែវ គាជាង២០ ហើយកាលជិនាន់ឥស្សរៈពួកកុំមុយនីស្តចូល ស្រុកខ្មែរមុនដំបូង ។

បូលីៈ គាថាឆ្លងកាត់សម័យអាណានិគម២០ឆ្នាំ?

នៅៈ ២០ឆ្នាំហើយ តាំងពីកើតមកដល់សន្ធិសិទ្ធសីណែរ៥៤ ខ្ញុំអាយុ២០ ។

បូលីៈ តាកើតឆ្នាំ៣៤?

នៅៈ ឥឡូវគិតទៅអាយុ២០ ឆ្នាំ៥៤អាយុ២០ ។

ដានីៈ តាកើតឆ្នាំខ្មែរឆ្នាំអីទៅ?

នៅៈ ឆ្នាំច ។

បូលីៈ ដូចខ្ញុំដែរ ។

នៅៈ ស្រករគ្នា ។

បូលីៈ ច ឡើងប៉ុន្មានជំនាន់ ច ៤-៥ជំនាន់ ។

ដានីៈ លោកតាឈ្មោះពេញ ឈ្មោះអីដែរ?

នៅៈ ឈ្មោះដដែលមិនដែលកែទេ ។

ដានីៈ ឈ្មោះអីទៅលោកតា?

នៅៈ ដាក់ ខៀវ នៅ ។

ដានីៈ លោកតាបួសអត់ដែលមានដូរឈ្មោះទេ?

នៅៈ ថែមផារក្នុងបាលី តែត្រូវកែទេនាមខ្លួន អាហ្នឹងនាមម៉ែឪ ដូនតាមកឈ្មោះតែប៉ុណ្ណឹង ។

ដានីៈ លោកតាអ្នកស្រុកកំណើតនៅណាដែរ?

នៅៈ នៅតាកែវ ។

ដានីៈ នៅភូមិអី ឃុំអីដែលលោកតា?

នៅៈ សាលាស្រុកអង្គតាសោម គេហៅស្រុកត្រាំកក់ ។

ដានីៈ ភូមិអី?

នៅៈ ឃុំត្រពាំងធំ ។

ដានីៈ ភូមិអីដែរ?

នៅៈ កាលកើតភូមិហ្នឹងភូមិត្រពាំងគល់ ។

ដានីៈ ហើយលោកតាកាលហ្នឹង លោកតាកើតនៅក្នុងត្រកូលអីដែរ?

នៅៈ អ្នកស្រែចំការធម្មតាទេ គ្រាន់តែមួយភូមិហ្នឹងចូលចិត្តរៀនសូត្រ បួនយាយហ្នឹងរៀនសូត្រ អីមក ពីដើមអត់មានសាលាទេ ច្រើនតែបួសរៀនបាលី បើខ្ញុំរៀនពួកអាចារ្យបាលីដដែរ ។

ដានីៈ ឪពុកលោកតាគាត់ព្រះនាមអីដែរ?

នៅៈ ណុប ឪពុកគាត់គ្មានបាននេះទេ គាត់នៅតែវត្ត ។

ដានី៖ ម្ដាយបង្កើត?

នៅ៖ ម្ដាយនាម សូវ ។

ដានី៖ លោកតាបងប្អូនលោកតាបង្កើតប៉ុន្មានដែរ?

នៅ៖ ៨តែនៅសល់តែ១ ។

ដានី៖ ទាំងអស់៨នាក់?

នៅ៖ ៨ តែស្លាប់នៅតូចៗអស់ទៅ មានអាយុ២០ ចុងក្រោយបងស្អស់អាមួយធ្វើគ្រូបង្រៀន ស្លាប់អាយុ២៧ ឆ្នាំ៧០ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅក្នុងចំណោមបងប្អូន?

នៅ៖ ស្រីតែ២ទេ តែស្រីស្លាប់ក្រោយ តែឥឡូវស្លាប់អស់ហើយ ខ្ញុំកូនទី៤ ។

ដានី៖ លោកតាកូនទី៤ ហើយសព្វថ្ងៃនេះក្នុងចំណោមបងប្អូនលោកតា៨នាក់ នៅសល់តែលោកតាម្នាក់ទេ?

នៅ៖ សល់តែមួយទេ ។

ដានី៖ លោកតាដូចថាជីវភាពក្នុងក្រុមគ្រួសារលោកតាកាលពីក្មេង យ៉ាងម៉េចដែរ? ធូរធារ?

នៅ៖ វាមិនអីទេ វាល្មម មិនក្រ មិនមាន ក្នុងភូមិហ្នឹងគេហៅថាភូមិមានធម៌ មានអាចឹអត់សូវ វង្វេងស៊ីដីកអាលាតែទេ បើមិនមាន ក៏មិនក្រដែរ អ្នកខូចពីណាទៅដល់ភូមិហ្នឹងឈប់ដឹក ហើយ ប្អូនតាខ្ញុំបង្កើតក៏សង្ឃរាជ ប្អូនយាយពីរសុទ្ធតែអាចារ្យ ចូលទៅឥទ្ធិពលហ្នឹង ។

ដានី៖ លោកតាកាលពីក្មេងចាប់ផ្ដើមចូលរៀនសាលា ចាប់តាំងពីអាយុប៉ុន្មាន?

នៅ៖ អត់ដែលបាននៅសាលាទេ នៅតែវត្ត ។

ដានី៖ ពីអាយុប៉ុន្មានទៅបានលោកតាទៅនៅវត្ត?

នៅ៖ ចេះវេញខ្សែ ចេះភ្ជួរខ្លះហើយបានទៅ មានបងមួយបង្រៀន រៀនសាលា រៀនៗបានដល់ត្រឹមអន្តតាសោមក៏ស្លាប់ទៅ ហើយយើងមានបានអីចេះតែខំ ៣ឆ្នាំ អាយុ១៦បានចូលបួស ចេះសំណាងតិចបានដាក់សាលាបាលី បួសបាន៣ខែចូលរៀនបាលី ហើយគ្មានដឹងង៉ង់អីទេ ព្រោះមិនបានចូលរៀនសាលានឹងគេ ។

ដានី៖ អីចឹងកាលពីក្មេងលោកតាអត់បានចូលរៀនសាលាទេ?

នៅ៖ អត់ទេ ។

ដានី៖ នៅធ្វើស្រែ ធ្វើចំការជាមួយឪពុកម្ដាយរហូតដល់១៦ទើបលោកតា?

នោះ	ធ្វើស្រែ តែអាយុ១១-១២ ឪពុកស្លាប់ អាហ្នឹងហើយដែលអត់បានទៅរៀន ឪពុកមុនស្លាប់គាត់ឈឺយូរដែរ គ្រាន់តែពូជរៀនសូត្រចេះតែឈ្មុលទៅៗ ។

ដានី៖	លោកតាតាំងពីជំនាន់លោកតានៅត្រពាំងគល់ នៅភូមិហ្នឹងច្រើនជាអ្នករៀនសូត្រ កាលហ្នឹងនៅក្នុងភូមិមានមនុស្សរស់នៅប្រហែលជាប៉ុន្មានគ្រួសារ?

នោះ	តិចទេ មួយពូជ ផ្ទះ៤-១០ ។

ដានី៖	ហើយ៤-១០ហ្នឹងសុទ្ធតែបងប្អូនគ្នា?

នោះ	ហ្នឹងហើយ មួយពោះ គេហៅពូជតាអ៊ុង យាយខៀវ ។

ដានី៖	ពូជតាអ៊ុង យាយខៀវ តាអ៊ុងហ្នឹងត្រូវជាជីតាលោកតា?

នោះ	តាទួតហើយ ហ្នឹងហើយតារបស់ តាម៉ុក ។

ដានី៖	លោកតាហើយ តាម៉ុក ត្រូវម៉េចនឹងគ្នា?

នោះ	គាត់ជួរលើខ្ញុំជួរខាងក្រោមទេ តាអ៊ុង ហ្នឹងតាទួតហើយ ។

ដានី៖	ជួរលើ ជួរក្រោមម៉េច?

នោះ	ចុះខ្ញុំចៅទួត នោះចៅបង្កើត ។

បូលី៖	គាត់ក្មួយរបស់តាម៉ុក ។

ដានី៖	តាម៉ុក គាត់ចៅរបស់តាអ៊ុង បង្កើត ដល់លោកតា ត្រូវជាចៅទួតរបស់តាអ៊ុង?

នោះ	ហ្នឹងហើយ ។

ដានី៖	អ៊ីចឹងលោកតាជាក្មួយរបស់ តាម៉ុក បង្កើត?

នោះ	បង្កើតម៉េច ថាត្រូវហើយ ម៉េចក្មួយបង្កើត ម៉េចក្មួយ ប្រយ័ត្នថាខុស ប្រយ័ត្នកត់ខុសតែមិនបានកត់ទេ ។

ដានី៖	តែហ្នឹងក្មួយម៉េច?

នោះ	ក្មួយបង្កើតទាល់តែក្មួយឯងពីរនាក់បងប្អូនបង្កើត បានកូនមកក្មួយបង្កើតហើយ បើជីដូនមួយអាហ្នឹងក្មួយជីដូនមួយ ។

ដានី៖	អ៊ីចឹងលោកតាត្រូវជាក្មួយជីដូនមួយ ។

នោះ	ហ្នឹងហើយ ។

ដានី៖	តែបើតាមវ័យវិញ តាម៉ុក ហើយនិងលោកតាវ័យ?

នោះ	គាត់បងច្រើនណាស់ បងជិត១០ឆ្នាំ ។

ដានី៖	ដូចពូជរបស់តាអ៊ុង ហ្នឹងក្នុងចំណោមហ្នឹងសុទ្ធតែអ្នករៀនសូត្រដល់ណា?

នោះ: អ្នករៀន អ្នកសូត្រ ឪពុករបស់តាម៉ុក ក៏អាចារ្យ អ៊ំតាម៉ុក ក៏អាចារ្យ ប៉ុន្តែមានមួយអត់ចេះអក្សរទេ ឪតាម៉ុកហ្នឹង អ៊ំមួយហ្នឹងគាត់ចេះច្រើនដែរ ខ្ញុំនៅចាំបានថាកាលឃើញគេធ្វើតូបបង្រៀនបាលី ហ្នឹងឪពុកតាម៉ុក ។

ប៊ូលី: ឪពុកតា ឬម្ដាយតា ត្រូវជីដូនមួយជាមួយ តាម៉ុក?

នោះ: ខាងម្ដាយ តិចយកទៅកាត់ទោសជាមួយ តាម៉ុក ទៅ?

ប៊ូលី: តាម៉ុក គាត់ខូចយកទៅកាត់ទោសណាកើត ។

ដានី: លោកតាបន្តមកទៀត កន្លែងដែលលោកតាចូលទៅបួស លោកតាថាបួសអាយុ១៦ហ្នឹងបួសនៅវត្តណាទៅ?

នោះ: ត្រពាំងធំ ។

ដានី: វត្តត្រពាំងធំតែម្ដង?

នោះ: ហ្នឹងហើយ ។

ដានី: ពេលចូលបួសហ្នឹងលោកតាចូលរៀនសាលាបាលីនៅវត្តហ្នឹង?

នោះ: ចូលបាលី រៀនបាលីតែម្ដង ។

ដានី: លោកតាអាចរៀបរាប់ថាពេលលោកតា ចូលបួសដំបូងយ៉ាងម៉េច? ហើយចាប់ផ្ដើមរៀនហ្នឹងរហូតយ៉ាងម៉េច បានតាមដំណាក់ៗ?

នោះ: រៀនហ្នឹងមិនបាននេះទេ រៀនបានបន្តិចវ៉ៃគ្នា ព្រោះនៅក្នុងសង្គ្រាមឥស្សរៈ អាចារ្យរត់ចុះរត់ឡើង មិនបានពេញឆ្នាំ ទីណាត់ទីណែងចេះតែដើរទៅនៅ អង្គរការ ទៅចំប៉ា ៥៤បាន ប្រឡងយកសញ្ញាប័ត្រឡារ៉េវងហើយ ហើយយើងចេះទៅ ដល់ប៉ុណ្ណឹងហើយទៅភ្នំពេញៗក៏អត់មានជាប់លាប់ដែរ ទៅមកៗ ជួយបង្រៀនខ្លះនៅវត្ត ទៅប្រឡងហ្នឹងក៏មិននេះដែរ រៀនគ្មានលំដាប់លំដោយ ឆ្នាំខ្លះក៏ខាន ខ្លះរៀនទៅ វាដាច់រយៈ ។

ដានី: លោកតាពេលដែលរៀននៅវត្តត្រពាំងធំបានប៉ុន្មានឆ្នាំ?

នោះ: រៀនមួយឆ្នាំ ឆ្នាំក្រោយចេញទៅអង្គរការ មកពីអង្គរការវិញមកត្រពាំងធំមួយឆ្នាំវិញ ។

ដានី: ដល់ឆ្នាំ៥៤មកភ្នំពេញ?

នោះ: ៥៥ហើយឯករាជ្យ ។

ដានី: ឯករាជ្យហើយភ្នំពេញ មកវត្តណាទៅ?

នោះ: វត្តមហាមន្ត្រី ។

ដានី: លោកតាកាលពីជំនាន់លោកតារៀន រៀនជំនាន់ណាខ្លះទៅ? ជាមួយស្របាល់ៗស្រករគ្នា

នោះ	ស្រករគ្នាអ្នកស្រុកស្លាប់អស់ទៅហើយ បង៦ក ធ្វើអាចារ្យវត្តមួយ តែអាចារ្យវត្តហ្នឹងរៀនបានតិចទេឈប់រៀន ក្រៅពីហ្នឹងច្រើនតែស្លាប់ខ្លះ ចាស់ប្លួស ។

ដានី៖	ជំនាន់ពីណាខ្លះដែលលោកតាចាំឈ្មោះ?

នោះ	នៅក្នុងស្រុកខ្ញុំ បងខែង គាត់៨៥-៨៦គាត់លែងសូវចាំអីហើយ ហើយនៅសល់តែ ៦កអាចារ្យវត្តរៀនជាមួយគ្នាបានបន្តិច គេសឹកទៅ គេទៅរកស៊ីនេះ រកស៊ីនោះអត់បានជាប់លាប់ជាមួយគ្នា ខ្លះរៀន១អីចឹងទៅសឹកទៅរៀនខាងក្រៅ ប្រឡងគ្រូ ធ្វើគ្រូ អត់មានអ្នកដែលជាប់លាប់ ។

ដានី៖	ប៉ុន្តែពេលលោកតាមករៀននៅវត្តមហាមន្ត្រីហ្នឹង យើងចាប់ផ្ដើមរៀនត្រឹមណាទៅ?

នោះ	ហ្នឹងវានៅសាលាបាលីរផងដែលហ្នឹង រៀនដដែល១ហៅថាឧបរិញ ។

ដានី៖	លោកតាចាំថានៅវត្តត្រពាំងធំហ្នឹង ជំនាន់មុនលោកតា ជំនាន់ក្រោយលោកតាដែលបានមករៀននៅមហាមន្ត្រីហ្នឹងបានប៉ុន្មាននាក់ដែរ?

នោះ	ពីមុនមកមានតែអាហ្នឹងវាហួសហើយយើងអត់ដឹងថានេះទេ នៅចាំថាពូជខ្ញុំមានអាចារ្យពីរដែលទៅរៀននៅណាខ្លះទេ ប្អូនយាយខ្ញុំមានអាចារ្យពីរ ។

ដានី៖	អាចារ្យឈ្មោះអីខ្លះទៅ?

នោះ	ស្លាប់បាត់តាំងពីនៅកំលោះនោះមួយ ។

ដានី៖	គាត់ឈ្មោះអីដែល គាត់ស្លាប់ទៅហ្នឹង?

នោះ	តាញឹម សឹកបានបន្តិចស្លាប់ ។

ដានី៖	ហើយមួយទៀត?

នោះ	មួយទៀត តាព្រៀក ។

ដានី៖	គាត់អាចារ្យហ្នឹងគាត់រៀបចំបានអី?

នោះ	ពីដើមគ្មានរៀប គ្មានថ្នាក់ទេ គាត់ចេះតែចូលរៀន ប្រែបាលីហ្នឹងទៅ អន្តុយរៀនបត់ជើង

ដានី៖	បន្ទាប់ពីអាចារ្យពីរនាក់ហ្នឹង មានលោកតាអាចារ្យណាទៀតដែលបានរៀនបន្តពីគាត់?

នោះ	ដល់មកមា មាខ្ញុំអត់ទេ អត់មានទេ រៀនល្មម១ក៏នាំគ្នាសឹកហើយស្លាប់អស់ហើយ ក្នុងវង់ហ្នឹងតមកក្រោយហ្នឹងដែលនៅបានយូរ ដូចខ្ញុំនៅដល់អាយុ៤២បានសឹក ។

ដានី៖	ចុះលោកតា តាម៉ុក គាត់បានរៀនមកវត្តដែរ?

នោះ	បានរៀនតិចតួចទេ ៦-៧ឆ្នាំហ្នឹង មិនដល់១០ផង ។

ដានី៖	រៀននៅវត្តមហាមន្ត្រីបានប៉ុន្មានឆ្នាំ?

នោះ: អត់ទេ មិនមែនមហាមន្ត្រីទេ វត្តកែវព្រះភ្លើង ។

ដានី: គាត់រៀនបានប៉ុន្មានឆ្នាំនៅកែវព្រះភ្លើង?

នោះ: មិនច្បាស់ទេ គ្រាន់តែលឺគាត់ថាៗ កាលហ្នឹងខ្ញុំមិនទាន់នៅវត្តផង ។

បូលី: នៅណាវិញកែវព្រះភ្លើងហ្នឹង?

នោះ: កែវព្រះភ្លើង ទៅខាងត្បូងវិមានឯករាជ្យក្បែរមាត់ទន្លេទៅត្បូងទៅ វត្តស្វាយពពែ ។

ដានី: ចន្លោះផ្លូវពីខាងជិនារវត្តស្វាយពពែមកមុខទៀត ហួសទូតសូវៀត ។ លោកតាអញ្ជើញមក នៅវត្តនៅខាងមហាមន្ត្រី តាម៉ុក ឈប់នៅវត្តហើយ?

នោះ: គាត់សឹកមកប្រពន្ធហើយខ្ញុំមិនទាន់បួសផង ។

ដានី: លោកតាជំនាន់ក្រោយលោកតាទៀត មានអ្នកមករៀននៅវត្តមហាមន្ត្រីទៀតដែលអត់?

នោះ: មានតិចៗបាត់ ។

ដានី: លោកតាចាំឈ្មោះអ្នកដែលមករៀននៅវត្តមហាមន្ត្រី ចេញពីត្រពាំងធំមកដែរ?

នោះ: បងខេង, បងសឿង, សុទ្ធតែបងៗខ្ញុំ ខ្លះក៏មកតិចតួច ប្អូនខ្ញុំមកមិនទាន់បាន១វស្សាផង ទៅបាត់ គាត់ស្លាប់បាត់ហើយ គ្នាអត់បានឈ្មោះថារៀនសូត្រផង ។

ដានី: ពីណាខ្លះ ដែលលោកតាចាំថាជាប់សាច់ញាតិ ដូចជា ព្រោះលោកតាមានប្រសាសន៍មិញ

នោះ: ក្នុងហ្នឹងចេះ មកឯករាជ្យមិនសូវមានបួសទេ រៀនសាលា ដូចប្អូនខ្ញុំរៀនសាលាបានឌីប្លូម ហើយក៏ប្រឡងខាងហុមម៉ាស្យុងជាប់ទៅធ្វើគ្រូ ហើយមួយទៀតនៅស្រះឈូកហ្នឹងត្រូវជាមា គេបានបាក់ឌុបគេហុមម៉ាស្យុងដែរ ជាង១០ចោរបាញ់ស្លាប់ហើយ ។

ដានី: គាត់ឈ្មោះអីខ្លះទៅ?

នោះ: ឈ្មោះ លាវ ។

ដានី: ឈ្មោះអីទៀត?

នោះ: ម៉ុក ម៉ារ៉េត ។

ដានី: គាត់រដ្ឋមន្ត្រីរាល់ថ្ងៃៗ ហើយពីណាទៀត?

នោះ: ប្អូនស្រីហ្នឹង តែស្លាប់ហើយ ឈ្មោះ យើន គិតទៅអ្នករៀនសាលានៅសល់តែមួយហ្នឹង ។

ដានី: សល់ពីណា?

នោះ: ម៉ុក ម៉ារ៉េត ហ្នឹង ប្អូនស្រីក៏ស្លាប់ លាវ ហ្នឹងនៅស្រះឈូកនេះក៏ស្លាប់ ប្អូនខ្ញុំក៏ស្លាប់ សុទ្ធតែស្លាប់ តែលាវ ហ្នឹងស្លាប់ចោរបាញ់ទេ ឯប្អូនខ្ញុំស្លាប់នឹងជំងឺទេ ហើយប្អូនម៉ុក ម៉ារ៉េត ប្អូនស្រីនោះស្លាប់ពេលឆ្លងទន្លេ អត់មានឈឺទេ ។

ដានី៖ ពេលលោកតាមកឆ្នាំ៥៥ មកវត្តមហាមន្ត្រីហ្នឹងបានប៉ុន្មានឆ្នាំ បានត្រឡប់ទៅវត្តត្រពាំងធំវិញ?

នៅ៖ ប្រហែលឆ្នាំ៧០ បានបកទៅវិញ ។

ដានី៖ ដល់រដ្ឋប្រហារឆ្នាំ៧០ បានបកត្រឡប់ទៅវត្តត្រពាំងធំវិញ ។ ពេលរដ្ឋប្រហារឆ្នាំ៧០ហ្នឹងលោកតារៀនដល់ថ្នាក់ណា?

នៅ៖ ខ្ញុំបានតែមកទេ អត់បានទៅលទ្ធផលទេ ព្រោះរៀនអត់នឹងធន់ ។

ដានី៖ អត់បានសញ្ញាបត្រចប់សាលាបាលីរង ជាន់ខ្ពស់?

នៅ៖ បានបាក់ឌុបដែរ ។

ដានី៖ បានសញ្ញាបត្របាក់ឌុប?

នៅ៖ បាន ។

ដានី៖ តែអត់បានតទៅទៀតទេ?

នៅ៖ អត់ទេ វាកើតការឈឺសុខភាពក៏ខ្សោយ ។

ដានី៖ លោកតាបន្ទាប់ពីឆ្នាំ៧០ ម៉េចលោកតាត្រឡប់ទៅវត្តមហាមន្ត្រី?

នៅ៖ វាធ្លាប់សង្គ្រាមពីមុនមកញឹក ហើយមើលឃើញថាកើតសង្គ្រាមមិនចង់នៅកន្លែងចង្អៀតនៅក្នុងក្រុងភ័យ បើនៅក្រៅវាវាលស្រួលរត់ ។

ដានី៖ ប៉ុន្តែកាលហ្នឹងលោកតានៅជា?

នៅ៖ នៅបួស ៧៥គ្មានបំណងចង់សឹកទេ នឹកឃើញចប់សង្គ្រាមក៏ចេះតែនៅទៅ ។

ដានី៖ អីចឹងឆ្នាំ៧០ លោកតាត្រឡប់ទៅវត្តត្រពាំងធំវិញ?

នៅ៖ ហ្នឹងហើយ ។

ដានី៖ ទៅត្រពាំងធំវិញ លោកតាទៅជាយ៉ាងម៉េចវិញទៅ?

នៅ៖ ទៅសង្ឃរាជសឹក នៅគ្រប់គ្រងហ្នឹងទៅ សង្ឃរាជអត់តែងតាំងនៅមើលលោកហ្នឹងទៅ ។

ដានី៖ លោកតាឆ្នាំ៧០ ទៅវត្តត្រពាំងធំវិញទៅធ្វើសង្ឃរាជវត្តនៅហ្នឹង?

នៅ៖ សង្ឃរាជវត្តតែគ្មានអ្នកណាតែងតាំងទេ ចេះតែនៅមើល ហើយបង្រៀនលោកហ្នឹងទៅគ្រប់គ្រង ។

ដានី៖ កាលហ្នឹងមានលោកប៉ុន្មានអង្គនៅហ្នឹង? លោកតានៅចាំទេ ព្រះនាមអីខ្លះ?

នៅៈ	មួយចុងក្រោយហ្នឹងដែរ ចុងក្រោយក្មេងៗមកបួសមកពីសាលា ឈ្មោះ ខុន, ខន គគោក ហ្នឹងចុងក្រោយ ខ្លះទៅធ្វើទាហាន ខ្លះនៅស្រុក ខ្លះក៏ស្លាប់ទៅ ហើយខ្ញុំ៧៩ហ្នឹងប្រុចចូលព្រៃរហូតមក ។

ដានីៈ	អីចឹងលោកតានៅធ្វើសង្ឃរាជនៅវត្តត្រពាំងធំ រហូតដល់ឆ្នាំ៧៥?

នៅៈ	៧៥ ។

ដានីៈ	ហើយបន្ទាប់ពីឆ្នាំ៧៥ហើយយ៉ាងម៉េចទៀតទៅ? លោកតារៀបរាប់កន្លែងហ្នឹង?

នៅៈ	៧៥មានអី ជួយខាងសេដ្ឋកិច្ចដឹកជញ្ជូនចែករបបប្រជាជន ។

ដានីៈ	លោកតាអាចមានប្រសាសន៍ទាក់ទងនឹងមុនដាច់ឆ្នាំ៧៥ លោកតានៅបួសនៅឡើយទេ ម៉េចបានជាលោកតាសឹក ហើយបន្ទាប់ពីសឹកហើយទទួលខាងសេដ្ឋកិច្ច ម៉េចបានលោកតាសឹកហើយទទួលខាងសេដ្ឋកិច្ចវិញ?

នៅៈ	តាម៉ុក គាត់បង្ខំឲ្យធ្វើ កាលហ្នឹងគេចាយលុយ គាត់ថារកពួកស្មោះត្រង់ហ្នឹង អីចឹងវាអត់មានការងារអី បានឈ្មោះស្មោះត្រង់ហ្នឹង ហើយមានបញ្ហាឲ្យកត់ឥវ៉ាន់ អាហ្នឹងរឿងហ្នឹងរឿងខ្ញុំដែលគេយកទៅប្រើការ រឿងនៅស្មៀមមិនសូវមាត់ ហើយមិនដែលធ្វើមានរឿងអីឲ្យកើតដល់ស្រុក ដល់បង ដល់ប្អូន គេចេះយកប្រើការរឿងហ្នឹងទេ ហើយរឿងលទ្ធិនោះគេដឹងថាខ្ញុំអន្សមខ្ទេចហើយ និយាយឲ្យចប់មិនបាច់ដេញសួរច្រើនទេ ខ្ញុំតាំងពីឆ្នាំ៥១មកទល់ឥឡូវមិនដែលអត់សីលទេ ។

ដានីៈ	ខ្ញុំមានចំងល់បន្តិចកន្លែងហ្នឹងលោកតា កន្លែងខ្លះដូចថាវត្តខ្លះចាប់ពីវត្ត៧០ វត្តខ្លះអត់មានលោកទេ លោកសឹកអស់ហើយ តែលោកតារហូតដល់ឆ្នាំ៧៥បានសឹក ។

នៅៈ	មិនត្រឹមតែវត្តត្រពាំងធំទេ វត្តអង្គរការ វត្តផ្ទឹកជ្រៃ វត្តត្នោតជុំ នៅស្រុកត្រាំកក់គគ្រីកគគ្រេងហ្នឹង ខ្ញុំសឹកហើយលោកមូលទៅផ្ទឹកជ្រៃនៅគគ្រីកគគ្រេងទៀត ។

ដានីៈ	លោកតាពេលហ្នឹងពេលឆ្នាំ៧៥ លោកតាមានដាប់សាច់ញាតិជាមួយ តាម៉ុក ហើយលោកតាអត់មានបំណងចង់សឹកទេ លោកតាអត់និយាយជាមួយ តាម៉ុក ថាចង់បួសនៅតទៀត ឬនៅវត្ត?

នៅៈ	អាហ្នឹងមេឃរលំដាក់ត្រូវតែយល់ ភ័យទាំងអស់អត់ហ៊ានមាត់ ហ៊ានកទេ ភ័យណាស់ ហ្នឹងមេឃរលំដាក់ ។

ដានីៈ	អាចពន្យល់ពាក្យថា "មេឃរលំដាក់"?

នៅៈ	អស់មួយដែនដីយើងទៅណា គេចទៅណា ធ្វើម៉េចឲ្យនៅរស់ អាហ្នឹងនិយាយឲ្យចំ ។

បូលីៈ បងប្អូននៅខ្វាចទៀត?

នៅៈ យី គ្រាន់តែកូនក្មួយតាម៉ុក គិតានគាត់ជួយអត់រួចផង បានត្រឹមតែដេរហើយគេយកទៅវ៉ៃចោល បានត្រឹមតែដេរទេ អាហ្នឹងនិយាយឲ្យច្បាស់ អាហ្នឹងយើងអត់មានអាងទេ ឲ្យយល់កាលហ្នឹង នៅសាលាក្តីគ្មានចិត្តចង់អីតែចេះតែនៅៗ ហើយគ្មានបានធំអីបើតាមគាត់និយាយ នេះសូមជំរាប ។

ដានីៈ លោកតាពេលដែលបែកឆ្នាំ៧៩ហើយ បានសឹក?

នៅៈ ហ្នឹងហើយ ។

ដានីៈ លោកតាសឹកខ្លួនឯង ឬក៏គេមកប្រាប់ឲ្យសឹក?

នៅៈ គេប្រាប់ មានគេមកសួរខ្ញុំថាអ្នកណាអ្នកឲ្យសឹក ខ្ញុំថាអត់ចាំទេពេលហ្នឹង ក្មេងឈ្លបវាដើរប្រាប់ថាអង្គការឲ្យសឹក អីចឹងគ្មានបានកត់ទុក ។

ដានីៈ មុនសឹក ឬនៅបួសនៅឡើយមានជួបជាមួយ តាម៉ុក ដែរ?

នៅៈ កាលកំពុងតែសង្គ្រាមជួបញឹកដែរ ។

ដានីៈ តាម៉ុកគាត់មានដែលមានប្រសាសន៍ប្រាប់លោកតា យ៉ាងម៉េចទាក់ទងពីនយោបាយទាក់ទងពីសភាពការណ៍ស្រុកទេសកាលហ្នឹង គាត់មានដែលមានប្រសាសន៍ប្រាប់លោកតា?

នៅៈ គាត់និយាយតាំងពីសន្និសិទ្ធសីណែវនៅស្រុក និយាយចេះៗ ប៉ុន្តែយើងជជែកឲ្យឈ្នះ ដឹកនាំទៅវិញទៅមក ពួកកុំមុយនីស្តផ្លាស់ប្តូរវ៉ៃសាសនា ហើយយើងអ្នកសាសនាមិនវ៉ៃបកវិញ ទាញទៅទាញមកវាអត់ឈ្នះ អត់ចាញ់ ខ្ញុំក៏មិនចូលគាត់ គាត់ក៏មិនចូលខ្ញុំ តទល់គ្នាប៉ុន្តែមិនដែលធ្វើរឿងអីឲ្យល្អក់កករ តែគេច្រើនតែនិយាយបង្រៀនគ្នាចេះ ធ្វើម៉េចយកឲ្យតែបានទៅអត់អីទេ មិនអេចអូចរករឿងអីគេធ្វើវែងឆ្ងាយ ឲ្យធ្វើអីធ្វើហ្នឹង ឲ្យធ្វើហួសអត់ធ្វើទេ ។

ដានីៈ ប៉ុន្តែពេលដែលជួបជាមួយ តាម៉ុក លោកតាដូចថាជជែកវែកញែកអីចឹង តាម៉ុក អត់ដែលខឹងលោកតា?

នៅៈ អត់មានខឹងអីគ្នាទេ ព្រោះគាត់កាលយើងឈប់សង្គ្រាមមកហើយគាត់អត់ទាន់មានអំណាចដល់មកមានសង្គ្រាម ឆ្នាំ៧០ គាត់មានអំណាចតែគាត់អត់ទាន់នេះ ក៏គាត់អត់ទាន់ហ៊ានថាអីធ្ងន់ធ្ងរដែរ គាត់គ្រាន់តែបន្ទាប់ ។

ដានីៈ បន្ទាប់ថាម៉េច?

នោះ	បន្ទាប់បែបសាសនា អ៊ូ! ចាញ់គេហើយ ចាញ់គេៗ ឥឡូវខ្ញុំជូនន័យនេះមួយ មកដល់ព្រៃ ក៏នៅតែបន្ទាប់ខ្ញុំដែរ ថាជូនមួយ ពួកគានៅ ឯងពួកខុសលទ្ធិប្រជាធិបតេយ្យ ពួកអាចារ្យ ពួកភាគតិច បោះសន្លឹកឆ្នោតក៏ចាញ់គេហើយ អាហ្នឹងលេងកណ្ដាលហ្វូងមេៗ ធ្វើម៉េចឲ្យចាញ់ប្រៀបគាត់ ។

ដានី:	គាត់ថាម៉េច គាត់ថាពួកលោកតា ពួក?

នោះ	ពួកខុសមួយភាគតិច ពួកអាចារ្យមួយស្រុកខ្មែរមានប៉ុន្មាន អាចារ្យថ្នាក់ប៉ុណ្ណឹង កាន់សីលប៉ុណ្ណឹង រកបានមួយលាន យ៉ាងច្រើនមួយពាន់ចុះ ។

ដានី:	បានន័យថាគាត់បន្ទាប់លោកតា បន្ទាប់ថាពួកអាចារ្យខាងផ្នែកពុទ្ធសាសនា?

នោះ	ពួកអាចារ្យ ពួកពុទ្ធិសាសនាហ្នឹង ចុះកុំមុយនីស្តមិនដឹង ។

ដានី:	តែតាម៉ុក គាត់ធ្លាប់បួស ធ្លាប់រៀន គាត់ខាងពុទ្ធិសាសនាដែរ ធ្លាប់ដែរគាត់អត់គាំទ្រខាងសាសនាទេ?

នោះ	អាហ្នឹងវាចេះ បើយើងតាមមើលតាំងពីដើមទល់គ្នាចុង ចេះតែនាំគ្នាខូច ជ្រុលហើយចេះតែនាំគ្នាប្រយ័ត្នៗបន្ទាប់យកន័យ ដល់អស់ពីតាពត ខ្ញុំនិយាយអីៗគាត់អត់ថាអីទេ កាលនៅ តាពត ឲ្យតែភ្លាត់បន្តិចកុំនិយាយអីចឹង ខូចគ្នា និយាយឲ្យនេះទៅ ។

ដានី:	កាលជំនាន់ណាដែលនិយាយទៅខូចគ្នា?

នោះ	អត់ទេ នៅព្រៃ នៅភ្នំដងរែកហ្នឹង ។

ដានី:	កាលពីជំនាន់ណាដែលយើងអត់ហ៊ាននិយាយទាក់ទងគ្នា?

នោះ	ជំនាន់៣ឆ្នាំយើងម៉េចហ៊ាន ដល់អស់អំណាចនៅព្រៃហើយ ប្រកាសលុបបក្សយើងខូចអី យើងចេះនិយាយស្ងាត់ៗ ទៅ ។

ដានី:	កាលជំនាន់៣ឆ្នាំលោកតាអត់ហ៊ាននិយាយជាមួយតាម៉ុក ឬតាម៉ុក គាត់អត់ហ៊ាននិយាយ

នោះ	ខាងណាក៏ដោយ យើងខូចទាំងអស់ យើងប្រយ័ត្នទាំងអស់ អាហ្នឹងអីចឹង ។

ដានី:	ពេលដែលលោកតាសឹកឆ្នាំ៧៥ហើយ រយៈពេលប៉ុន្មានបានជួបជាមួយ តាម៉ុកៗ ចាត់តាំងឲ្យលោកតាកាន់ខាងសេដ្ឋកិច្ច?

នោះ	គាត់ ៣៨ សឹងមួយឆ្នាំ មុនដំបូងគិតបោះពុម្ពលុយរៀបចាយទៅហើយ ដល់នេះឈប់ចាយវិញ ហើយឲ្យទៅជួយខ្ញុំក៏ប្រកែកដែរ ការងារអីក៏ដោយម៉េចៗកុំឲ្យកាន់លុយ អ៊ើមិនមែនកាន់តែម្នាក់ឯង ដល់អត់ចាយលុយជួយមើលសម្ភារៈ ។

ដានី:	តាម៉ុក គាត់ហៅលោកតាទៅនៅជាមួយនៅណា?

នៅៈ នៅកន្ទួត ។

ដានីៈ សៀមរាប?

នៅៈ ហ្នឹងហើយ ។

ដានីៈ កន្ទួតសៀមរាបហ្នឹងកន្លែងអីគេបានលោកតាទៅនៅហ្នឹង?

នៅៈ កន្ទួតហ្នឹងអាស្នឹងកន្ទួតជិតផ្សារកំពង់ទួលខាងត្បូងភ្នំពេញហ្នឹង ។

ដានីៈ កន្លែងកន្ទួតសៀមរាបហ្នឹងខ្ញុំស្គាល់ហើយ តែកន្លែងហ្នឹងជាកន្លែងរបស់?

នៅៈ មិនមែននៅក្រុងភ្នាមទេ គាត់នៅភូមិភាគ ដល់ចុងក្រោយបានគាត់មកតាកែវ ។

ដានីៈ នៅកន្ទួតហ្នឹងកន្លែងមន្ទីរភូមិភាគនីរតី?

នៅៈ ហ្នឹងហើយគាត់នៅហ្នឹង ។

ដានីៈ គាត់នៅមន្ទីរភូមិភាគនីរតីគាត់ហៅលោកតានៅជាមួយគាត់?

នៅៈ ហៅទៅនៅជាមួយ ។

ដានីៈ នៅជាមួយលោកតាទទួលតួនាទី?

នៅៈ អត់ទាន់មានទទួលអីទេ ។

ដានីៈ នៅមន្ទីរភូមិភាគជាមួយគាត់?

នៅៈ ហ្នឹងហើយ គិតថាឲ្យកាន់លុយដល់ឈប់ចាយលុយទៅ ក៏នៅចោលហ្នឹង ។

ដានីៈ គំរោងដំបូងគាត់ឲ្យលោកតាកាន់លុយ?

នៅៈ ជួយកាន់លុយ ។

ដានីៈ ដល់ពេលអត់កាន់លុយ ក្រោយមកគេផ្លាស់យ៉ាងម៉េចទៀត?

នៅៈ នៅជួយដឹកជញ្ជូន ។

ដានីៈ ដឹកជញ្ជូននៅណា?

នៅៈ ដឹកជញ្ជូនទៅតាកែវ ទៅកំពត ។

ដានីៈ ដឹកជញ្ជូនហ្នឹងក្នុងភូមិភាគ ឬមជ្ឈឹម?

នៅៈ របស់ភូមិភាគទេ មិនមែនមជ្ឈឹម ។

ដានីៈ លោកតាអាចរៀបរាប់កន្លែងដឹកជញ្ជូនកាលហ្នឹង លោកតាចាប់ផ្ដើមទទួលខាងដឹកជញ្ជូន យើងចាប់ផ្ដើមដឹកជញ្ជូនយ៉ាងម៉េច? ជាកង ជាភារកិច្ច ជាតួនាទី?

នៅៈ ដឹកជញ្ជូនតាមឡាន តាមរទេះភ្លើង ទាក់ទងតាមរដ្ឋ គ្រាន់តែយកពីរដ្ឋយើងប្រគល់ទៅឡាន ទៅរទេះភ្លើង ទៅតាកែវយើងដាក់ទៅ ។

ដានី: បានន័យថាខ្ញុំចង់ដឹងថារបស់របរដែលយើងបានមកពីណា មកកន្លែងលោកតា ហើយលោកតាចែកចាយទៅខាងណាខ្លះ?

នៅ: យើងមានសំបុត្រតែនេះខាងឃ្លាំងរដ្ឋគេចេញឲ្យហើយ ចេញសំបុត្រឲ្យយើងទៅយក យកមកយើងរកឡានបានទៅជូនដាក់រទេះភ្លើងកន្លែងឆ្ងាយអី ។

ដានី: លោកតាមានប្រសាសន៍មិញថាឃ្លាំងរដ្ឋ ឃ្លាំងរដ្ឋពីភ្នំពេញចេញសំបុត្រឲ្យលោកតាមកយក

នៅ: ហ្នឹងចេញឲ្យគ្រប់ភូមិភាគ បើនិយាយឲ្យហួសព្រំដែនបន្តិច គ្រប់ភូមិភាគទាំងអស់ តែនេះខាងរដ្ឋចេញសំបុត្រឲ្យទៅយក ។

ដានី: ឃ្លាំងរដ្ឋចេញសំបុត្រឲ្យទៅយកហ្នឹង ទំនិញមានស្អីខ្លះទៅ?

នៅ: របស់ដែលប្រើ អាហ្នឹងចេះតែចែកទៅក្រៅឲ្យដុតបំភ្លឺទេ អាកន្លែងលក់ទៀន លក់ធូប លក់ក៏ដឹកជញ្ជូនឲ្យទៅក្រៅដែរ ហើយតាំងពីគុ ទូ កៅអី របស់ដែលនៅក្នុងភ្នំពេញជញ្ជូនយកទៅក្រៅ របស់ណាដែលអ្នកស្រុកប្រើបានយកទៅប្រើទៅ ។

ដានី: កាលហ្នឹងមានតាំងពីគ្រឿងសង្ហារឹមដែលគេប្រមូលតាមផ្ទះ យកមកដាក់ឃ្លាំងរួមហ្នឹងក៏យើងជញ្ជូនមកតាមភូមិភាគ?

នៅ: ចែកដល់អ្នកស្រុក ហើយក្រណាត់ ។

ដានី: មានអីទៀត?

នៅ: មានគ្រឿងដែក របស់ធំៗខាងរដ្ឋចែក ហើយតាមភូមិភាគស្នើរ ។

ដានី: ភូមិភាគច្រើនស្នើរអី?

នៅ: ខ្ញុំស្នើរតាំងពីដបដាក់ទឹកត្រី ព្រោះយើងកំពង់អំពិលធ្វើទឹកត្រីហើយអត់អីចែកប្រជាជន ហើយឃើញដបនៅទាំងកេះៗ ខ្ញុំស្នើរ ។

ដានី: លោកតាការដឹកសម្ភារៈហ្នឹង ដឹករយៈពេលប៉ុន្មានយើងដឹកម្តង ហើយដឹកទៅយើងដឹកយកទៅឃ្លាំងនៅភូមិភាគ ឬក៏?

នៅ: ដាក់ឃ្លាំងភូមិភាគ តែតាម៉ុក គាត់ច្រើនតែចេះ ជួនគាត់អត់ពិនិត្យទេ សួរអ្នកឡានថាប៉ុន្មានឡាន ៤ឡាន គាត់ថាទៅកំពតមួយឡាន ទៅកំពង់អំពិលមួយឡាន នៅតាកែវមួយឡាន គាត់មើលតាមឡាន ពេញៗឡានទៅៗកុំឲ្យយូរ ។

ដានី: បានន័យថាទៅតាមតំបន់ឬយ៉ាងម៉េច?

នៅ: ហ្នឹងហើយទៅតាមតំបន់ ។

ដានី: ដូចថាយើងមកបើកភូមិភាគហ្នឹង រយៈពេលប៉ុន្មានមកបើកម្តង?

នៅៈ អត់ដឹងទេ អ្នកនៅខាងភូមិភាគផ្ទាល់គេនៅផ្សេង ។

ដានីៈ លោកតាគ្រាន់ទទួលខាងដឹកជញ្ជូនមែន?

នៅៈ គ្រាន់តែជញ្ជូនយកទៅដាក់ទុកនៅឃ្លាំង អ្នកចែកផ្សេង ។

ដានីៈ គេអ្នកចែកទៀត?

នៅៈ អ្នកចែកផ្សេងទៀត យើងគ្រាន់តែដឹកជញ្ជូនពីភ្នំពេញ ។

ដានីៈ លោកតាទទួលដឹកជញ្ជូនមកភូមិភាគនិរតី?

នៅៈ ហ្នឹងហើយ ។

ដានីៈ យើងគ្រាន់តែទទួលរួមទេ?

នៅៈ ទទួលចេញពីភ្នំពេញ យកទៅទុកនៅឃ្លាំងតាកែវ ហើយមានគេអ្នកចាត់ចែងទៅ ។

ដានីៈ ប៉ុន្មាននាក់ក្រុមលោកតាដែលជាគណៈគ្រប់គ្រងហ្នឹង?

នៅៈ កាលហ្នឹងច្រើនដែរ ដល់តមកតិចទេ ។

ដានីៈ ប៉ុន្មាននាក់ទៅក្នុងគណៈគ្រប់គ្រង?

នៅៈ មានពួកឡាន៨-១០នាក់ ដល់យូរទៅវា ហ្នឹងហើយច្រើនតែពួកឡាន ។

ដានីៈ ប៉ុន្តែខ្ញុំចង់សួរនេះទាក់ទងខាងអ្នកដឹកជញ្ជូនអគ្គភាពដឹកជញ្ជូន មានគណៈគ្រប់គ្រងដឹកជញ្ជូន លោកតាអ្នកទទួលខុសត្រូវខាងដឹកជញ្ជូនម្នាក់ អ្នកដឹកនាំម្នាក់?

នៅៈ គ្រាន់តែម្នាក់ទេ តែមានគេប្រធានលើយើងទៀត ។

ដានីៈ មានប្រធានលើលោកតាទៀត?

នៅៈ ប្រធានទៀត ។

ដានីៈ ពីណាគេប្រធានលើលោកតា?

នៅៈ អាឈ្មោះ បូរាណ ស្លាប់បាត់ហើយ ។

ដានីៈ បូរាណ ត្រូវជា?

នៅៈ កូនប្រសារតាម៉ុក ។

ដានីៈ ហ្នឹងគាត់ប្រធានលើលោកតា?

នៅៈ ហ្នឹងហើយ ។

ដានីៈ ពីរនាក់ហ្នឹង មានអ្នកផ្សេងទៀត?

នៅៈ មានផ្សេងៗក៏ស្លាប់ ។

ដានីៈ ផ្សេងណាទៅ?

នោះ	ផ្សេងហ្នឹងមិនដឹងស្រុកគេនៅណា ស្លាប់បាត់យូរហើយ ។

បូលីៈ	បូរាណ ស្លាប់ប៉ុន្មានណាលោកតា?

នោះ	បូរាណ តាំងពីមិនដឹងឆ្នាំប៉ុន្មានទេ ជាន់មីនស្លាប់ពេលដឹកជញ្ជូន ។

ដានីៈ	ថាគាត់ពូកែខាងបាញ់ដីរី?

នោះ	ហ្នឹងហើយ ពូជគេហ្នឹង គេឲ្យមកពូកែខាងបាញ់ អាប្អូន អាវ៉ាល់ ក៏អីចឹងដែរ ពូកែបាញ់ត្រង់?

ដានីៈ	ឈ្មោះអី ឈ្មោះ រ៉េ?

នោះ	វ៉ាល់ តែស្លាប់អស់ហើយ ។

ដានីៈ	លោកតាកាលឃុំរដ្ឋនៅភ្នំពេញ ពីណាគេ?

នោះ	ពីមុនមកប្រធានគឺ វន វ៉េត ។

ដានីៈ	វន វ៉េត គាត់ទទួលខាងឃ្លាំងហ្នឹងតែម្តង?

នោះ	បងវ៉េត លឺសូរប្រកាសថា ឧបនាយករដ្ឋមន្ត្រី ហ្នឹងជាចំហរ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច៩ក្រសួង ។

ដានីៈ	ទទួលសេដ្ឋកិច្ច៩ក្រសួង?

នោះ	៩ក្រសួង សេដ្ឋកិច្ចទាំងអស់ ។

ដានីៈ	៩ក្រសួងហ្នឹង ក្រសួងអីខ្លះ?

នោះ	សេដ្ឋកិច្ច ឧស្សាហ៍កម្ម តាំងពីអីៗណាទាំងអស់ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងហ្នឹង ។

ដានីៈ	ប៉ុន្តែអ្នកដែលកាន់ឃ្លាំងរដ្ឋផ្ទាល់ពីណាគេ?

នោះ	ឃ្លាំងផ្ទាល់ រឿង តែស្លាប់បាត់ហើយ កាលហ្នឹងនៅក្នុងហ្នឹងតែបាត់ហើយ ។

ដានីៈ	តារឿង?

នោះ	ហ្នឹងហើយ ។

ដានីៈ	ចុះ តារិទ្ធិ?

នោះ	រិទ្ធិ ពាណិជ្ជកម្មក្រៅប្រទេស ។

ដានីៈ	តារឿង គាត់ទទួលខាងឃ្លាំង?

នោះ	ហ្នឹង ដល់អត់ វន វ៉េត ទៅតាខៀវ សំផន ។

ដានីៈ	តាខៀវ សំផន គាត់ចាប់កាន់ពីឆ្នាំណាទៅ?

នោះ	មិនចាំឆ្នាំទេ អត់ពី វន វ៉េត ។

ដានី៖ កាលហ្នឹងពេលលោកតាមកបើកពីឃ្លាំងរដ្ឋអីចឹង ពេលហ្នឹងយើងមកជួបជាមួយ វ៉ន វើត ផ្ទាល់ ជួបជាមួយ ខៀវ សំផន ផ្ទាល់ឬយ៉ាងម៉េច?

នោះ៖ អត់ទេ ពួកឃ្លាំងយកសំបុត្រពី រឿង ។

ដានី៖ សំបុត្រពីណា?

នោះ៖ តារឿង ។

ដានី៖ ប្រធានឃ្លាំងរដ្ឋ?

នោះ៖ សំបុត្រហ្នឹងចេញមកហើយយើងទៅដឹក យើងឲ្យអ្នកឡានបើកទៅ វាបើកអីបើកទៅ ពេលរាប់គ្រាន់តែពិនិត្យ ពិច័យទៅ ។

ដានី៖ ប៉ុន្តែលោកតាពេលចេញសំបុត្រពី រឿង ម៉េចបានលោកតាដឹងថា វ៉ន វើត គាត់ទទួលខុសត្រូវខាងឃ្លាំងរដ្ឋ តាខៀវ សំផន គាត់អ្នកទទួលខុសត្រូវបន្ទាប់ពី វ៉ន វើត?

នោះ៖ អាហ្នឹងមានគេប្រាប់ដែរ មានប្រាប់ថា វ៉ន វើត ក្រសួង ហើយដល់អត់ វ៉ន វើត ទៅទាក់ទងជាមួយលោក ខៀវ សំផន ដូច្នេះពីមុន វ៉ន វើត ធំមិនមែនលោក ខៀវ សំផន ទេ ហើយលោកខៀវ សំផន ប្រកាសថាប្រធានគណៈប្រធានរដ្ឋ ហើយ វ៉ន វើត អនុមិនមែនទេ នៅក្នុងគណៈប្រធាន តែមែនទែនអំណាចទាបជាង វ៉ន វើត ថ្នាក់ទាបជាង វ៉ន វើត ។

ដានី៖ ខៀវ សំផន ថ្នាក់ទាបជាង វ៉ន វើត?

នោះ៖ ថ្នាក់ទាបជាង បើអត់គេ បានទៅលើ ។

ដានី៖ លោកតាក្រៅពីយើងមកដឹកឥវ៉ាន់ពីខាងឃ្លាំងរដ្ឋទៅ ចុះពីខាងមូលដ្ឋានវិញ ពីខាងសហករណ៍ ពីខាងឃុំ ខាងស្រុក យើងមានដឹកពីខាងស្រុកមកខាងឃ្លាំងរដ្ឋវិញដែលអត់?

នោះ៖ អាហ្នឹងអត់មានអី អាហ្នឹងផ្សេងហើយ គេត្រូវការច្រើនដឹកទៅចែក ហើយមកវិញហ្នឹងរបៀបសុំអ្នកស្រុកមកទេ ។

បូលី៖ ស្រូវអង្ករ?

នោះ៖ ស្រូវអង្ករ អាហ្នឹងផ្សេង ។

ដានី៖ ផ្សេងហ្នឹងបានន័យថាគេអ្នកកាន់ គ្រប់គ្រងផ្សេង ឬក៏?

នោះ៖ អាហ្នឹងផ្សេងហើយ មានរយៈគេផ្សេងទៀត ។

ដានី៖ គេទទួលខុសត្រូវផ្សេង មិនមែនលោកតាជាអ្នកទទួលខុសត្រូវទេ?

នោះ៖ អាហ្នឹងគ្រាន់តែជួយដឹកចេញប៉ុណ្ណឹង ។

ដានី៖ តែលោកតាមានដែលដឹងរឿងថាបញ្ហាយើងត្រូវដឹកពីខាងមូលដ្ឋាន មកឃុំឃាំងរដ្ឋនៅភ្នំពេញវិញគេយ៉ាងម៉េចវិញ?

នៅ៖ អត់ដឹង អាហ្នឹងពួកសំឡឹក ខ្ញុំអត់ដឹងទេ គេដឹកមកខសម្រាប់ហកម្ម យើងអត់ដឹង ។

ដានី៖ ស្រូវ អង្ករក៏មិនដឹងដែរ?

នៅ៖ អត់ដឹង សូម្បីតែស្នើរសុំឥដ្ឋ កាលពីមុនស្នើរសុំ វាន វើត ដែរ ដឹកមកវិញអត់មានអីធំដុំណាដឹកមកវិញ ។

ដានី៖ នៅភូមិភាគនិរតីហ្នឹង តាម៉ុក គាត់ជាគ្រប់គ្រងនៅភូមិភាគនិរតីផ្ទាល់នៅហ្នឹង ចុះបន្ទាប់ៗអ្នកគណៈគ្រប់គ្រងភូមិភាគក្រៅពីតាម៉ុក មានអ្នកណាខ្លះ?

នៅ៖ មាន កង ចាប, ជូ ចេត ក្រោយៗមកបាត់អស់រលីងមិនដឹងទៅណា កង ចាប ចៅហ្វាយខេត្តកំពត ជូ ចេត ខាងបស្ចិម ដល់នេះបែកមួយភាគៗ ដល់នេះបាត់អស់ទៅហើយ សឿង នៅខាងទាហាន ស្លាប់បាត់ទៅ ។

ដានី៖ ចុះនៅនិរតីជាមួយ តាម៉ុក តែម្តងពីណាគេ? នៅគ្រប់គ្រងភូមិភាគនិរតី?

នៅ៖ ភូមិភាគនិរតីមុនដំបូងអត់ទាន់បែកភាគ ។

ដានី៖ មានកង ចាប មានជូ ចេត?

នៅ៖ កង ចាប និង ជូ ចេត មាន៣នាក់ហ្នឹង ។

ដានី៖ ដល់គេបែកភាគអស់ទៅ?

នៅ៖ បែកភាគទៅ ជូ ចេត មកខាងបស្ចិម ដល់បាត់អស់ទៅមិនដឹងម៉េច ។

ដានី៖ ចុះនៅនិរតីតែម្តង បន្ទាប់ពីបែកយើងយកពីណាទៀតមកជំនួស?

នៅ៖ បិត ស្លាប់ដែលហើយ កងពល១២ ។

ដានី៖ ពីណាទៀត ក្រៅពី តាបិត?

នៅ៖ អត់ទេ គណៈភាគតែម្តង នឹកមិនឃើញទេ ។

ដានី៖ កាលហ្នឹងភូមិភាគនិរតីមានប៉ុន្មានតំបន់?

នៅ៖ តាកែវ កំពត កំពង់ឆ្នាំង ខេត្តកណ្តាល កំពង់ស្ពឺ ។

ដានី៖ តាកែវ កាលហ្នឹងតំបន់ប៉ុន្មាន?

នៅ៖ ១៣ ។

ដានី៖ ពីណាគណៈតំបន់កាលហ្នឹង?

នៅ៖ គណៈតំបន់មុនដំបូង មាស មុត ដល់បានបន្តិចបាត់ទៅ ។

ដានី៖ មាស មុត ដំបូង ហើយបន្ទាប់ពី តាមុត ចេញមកពីណាគេជំនួស?

នៅ៖ ដូចនឹកមិនឃើញ ។

បូលី៖ ខុម?

នៅ៖ អត់ទេ ។

ដានី៖ តាសោម?

នៅ៖ ភ្លេច សោម ប្រធាន មុត អត់ប្រធានទេ ។

បូលី៖ អនុ ។

ដានី៖ តាមុត អនុ តាសោម ប្រធាន?

នៅ៖ ដល់ពីរនាក់ហ្នឹងចេញមក មិនដឹងណាជាអ្នកណា ។

ដានី៖ ហើយតំបន់ផ្សេងទៀត ដូចតំបន់កំពត?

នៅ៖ កំពត ពីមុនមកមាន កង ចាប ហើយនិង រិន ដល់ កង ចាប ហ្នឹងក៏បាត់ រិន ហ្នឹងក៏បាត់ ស្លាប់អស់ហើយពួកហ្នឹង ។

ដានី៖ ហើយខាងកណ្ដាល?

នៅ៖ កណ្ដាលមាន ប្រាក់ មាន ជា តែបាត់ទៅមិនដឹងម៉េច ខ្ញុំធ្លាប់ដឹកឥវ៉ាន់យកទៅឲ្យ ។

ដានី៖ ធ្លាប់ដឹកឥវ៉ាន់ទៅជួប?

នៅ៖ ទៅខ្ញុំទៅជួប នៅភ្នំពេញរកផ្ទៃទឹកដោះ ។

ដានី៖ លោកតាធ្លាប់ដឹកទៅដល់ស្រុកអត់?

នៅ៖ ទៅយូរៗទៅម្ដង ។

ដានី៖ ធ្លាប់ទៅស្រុកណាខ្លះទៅ?

នៅ៖ ទៅអត់ទៅឆ្ងាយ ខ្ញុំទៅតែស្រុកកំណើត ។

ដានី៖ ទៅខាងត្រាំកក់?

នៅ៖ ហ្នឹងហើយ ទៅតែមួយដូរហ្នឹងទេ ទៅលេង ហើយទៅស្រុកផ្សេងៗអត់ទេ ។

ដានី៖ ហើយធ្លាប់ទៅជួប យាយរ៉ាន់ ទេ?

នៅ៖ ពួកហ្នឹងជួបតាំងពីយូរមកហើយ ស្រុកជិតគ្នាចេះតែជួប ។

ដានី៖ កាលហ្នឹងគាត់នៅណា យាយរ៉ាន់?

នៅ៖ នៅណាទេ ដូចខាងអង្គរជ័យ ដល់ក្រោយមកនៅខាងពេទ្យ ដូចត្រឡប់ត្រឡិន ។

ដានី៖ ដល់ យាយចែម ក៏ធ្លាប់ជួបគាត់ដែរ?

នោះ: ជួបមិនជួបការងារទេ ។

ដានីៈ ជួបគាត់នៅតាកែវឬ?

នោះ: កន្លែងខ្ញុំនៅភ្នំពេញ ជួនឆ្លងគាត់ចូលមកស្នាក់ផ្ទះខ្ញុំ ។

ដានីៈ យាយថែម គាត់ចូលមកស្នាក់នៅផ្ទះជាមួយលោកតាដែរ?

នោះ: ហ្នឹងហើយ ជួនមកស្នាក់នៅ ជួនទៅធ្វើការនៅលើ មកស្នាក់នៅហើយបានទៅ ។

ដានីៈ កាលហ្នឹងគាត់នៅក្នុងគណៈតំបន់១៣នៅតាកែវ ឬគាត់នៅស្រុក?

នោះ: កាលមុននៅស្រុកកៀនស្វាយទេ ហើយមានស្អីណាក៏បាត់ទៅ ។

ដានីៈ នៅណា?

នោះ: មិនសូវចេះ ។

ដានីៈ តាទិត?

នោះ: មិនមែនទេ ទិត ហ្នឹងក៏អត់ច្បាស់ដែរ ទិត ផ្សេងផ្សំចុះឡើងៗគ្រាន់តែមកនៅមន្ទីរទេ ។

ដានីៈ តាទិត គាត់ធ្លាប់មកនៅមន្ទីរ?

នោះ: មន្ទីរតាម៉ុក ហ្នឹង ។

ដានីៈ កន្លែងមន្ទីរភូមិភាគ ឬក៏មន្ទីរ?

នោះ: មន្ទីរភូមិភាគ ។

ដានីៈ គាត់មកធ្វើគ្រប់គ្រងនៅមន្ទីរហ្នឹង?

នោះ: ហ្នឹងហើយ តែក៏មិនយូរដែរ ក្រោយមកទៅស្រុកបាត់ដំបង ធ្វើប្រធាន ឬអនុស្អីគេ ។

ដានីៈ ពីណាគេមកក្រចេះ?

នោះ: ក្រចេះដូច មឿន អាហ្នឹងមកពីកៀនស្វាយ អាហ្នឹងក៏បាត់អស់ស្លាប់អស់ ។

ដានីៈ មិនមែន យាយបូ ទេ?

នោះ: អត់ទេ ។

ដានីៈ យាយបូ គាត់គណៈស្រុកកៀនស្វាយ?

នោះ: កៀនស្វាយ មឿន ហ្នឹងដូចមកក្រចេះ ហើយស្លាប់បាត់ហើយ ។

ដានីៈ អ៊ីកាលជំនាន់ហ្នឹងយើងហូបចុកយ៉ាងម៉េចដែរ? ដូចជាប្រជាជនទូទៅនៅខេត្តតាកែវ ឬចំពោះកម្មាភិបាល?

នោះ: យើងអត់ដឹងទេ យើងមិនបានដឹង គ្រាន់តែលឺតៗ មានពេលមួយចេះ ញាន់ តែស្លាប់ហើយខ្ញុំទើបមកនៅកន្លែងគាត់ ញាន់ គេមករាយការណ៍ឲ្យតាម៉ុក ពួក១៧អាក្រក់ណាស់

អាសំបកខ្មោរនៅគុម្ពចេកមកដណ្ដើមគ្នា តាម៉ុក គាត់ភ្ញាក់មាត់បន្ដិចដែរ ចុះម៉េចមិនវៃបំបែកក្បាលម៉េចទុក គាត់ថាណែ៎ៗបាយជាមួយប្រជាជន អីចឹងវាស្លាប់ប្រជាជនអស់ ហ្នឹងរឿងឃ្លាន គាត់ប្រាប់ថាហ្នឹងហើយរឿងឃ្លាន ធ្វើឲ្យស្រួលបួលតែមិនបាយប្រជាជនហើយដល់ស្ងាត់ៗគាត់និយាយរឿងគោស៊ីស្លឹកត្នោត ស៊ីដំបូលផ្ទះ គោដល់អត់ដឹកវាទៅក្រៅឲ្យស៊ីស្មៅ ដល់ឃ្លានវាបោចដំបូលផ្ទះ គាត់ដំណាលរឿងហ្នឹងប្រាប់ ។

ដានី៖ ខ្ញុំដូចអត់ទាន់ច្បាស់លោកតា កន្លែងហ្នឹងដូចថាពេលដែល ញាន់ មករាយការណ៍ប្រាប់តាម៉ុក ថាអ្នក១៧មេសា ដណ្ដើមសំបកខ្មោរហូបហ្នឹង?

នៅ៖ មកកន្លែងមន្ទីរឃុំ ហើយឃើញសំបកខ្មោរ ។

ដានី៖ ហើយ តាម៉ុក គាត់ភ្ញាក់មាត់ថា តាញ៉ា ហ្នឹងមិន ។

នៅ៖ វៃបំបែកក្បាល ដល់ហើយភ្លាមហ្នឹង ន៎ែៗឃើញទេ តែមិនបាយជាមួយសហករណ៍ជាមួយប្រជាជនស្លាប់ប្រជាជនហើយ ។

ដានី៖ បានន័យថាខាងកម្មាភិបាលហូបបាយផ្សេង ប្រជាជនហូបបាយផ្សេង?

នៅ៖ ហ្នឹងហើយ ឲ្យបាយជាមួយប្រជាជន មិនអីចឹងស្លាប់ប្រជាជនហើយ ដល់យប់ឡើងបាននិយាយប្រាប់ខ្ញុំរឿងគោស៊ីស្លឹកត្នោត ។

ដានី៖ រឿងគោស៊ីស្លឹកត្នោតយ៉ាងម៉េច? ពីណាគេអ្នកដែលយក?

នៅ៖ គោស៊ីស្លឹកត្នោតកាលគាត់នៅស្រុកពីដើម គាត់រវល់ទៅនេះទៅនោះ គោចងអត់យកទៅក្រៅ អាដំបូលប្រក់ស្លឹកត្នោតគោវាស៊ីស្លឹកត្នោត ។

ដានី៖ ប្រជាជនគាត់ចងគោចោលអត់យកឲ្យស្មៅស៊ី ឬយ៉ាងម៉េច?

នៅ៖ ប្រជាជនអីខ្លួនគាត់ហ្នឹងកាលមិនទាន់ធ្វើការ ទើបតែសឹកពីបួសនោះ ។

ដានី៖ តាញាន់ ហ្នឹង?

នៅ៖ អត់ទេ តាម៉ុក កាលពីគាត់សឹកពីបួសគាត់មានទាន់ធ្វើអី គាត់រកស៊ីធម្មតា ហើយចងគោចោលហើយគាត់រវល់តែដើរ ហើយយាយគាត់ ក៏អត់ដឹងទៅក្រៅ មានអីគោស៊ីត្នោតគាត់ថាមិនបានទេរឿងឃ្លាន ។

ដានី៖ កាលហ្នឹងផង តាញាន់ គាត់ធ្វើអីគេ?

នៅ៖ ប្រហែលជាឃុំហើយ ។

ដានី៖ ឥឡូវគាត់នៅណាដែរទៅ?

នៅ៖ ពីដើមអន្លង់វែងតែស្លាប់ហើយប្រហែលមួយឆ្នាំ ។

ដានី៖ គាត់នៅណាអន្លង់វែង?

នៅ៖ ថ្វាត ។

ដានី៖ អីចឹងបើសិនជានៅតាមស្រុក នៅតាមមូលដ្ឋាន សហករណ៍ តាមឃុំ លោកតាអត់ដឹងថាពួកគាត់ហូបចុកម៉េចទេ?

នៅ៖ ដឹងខ្លះ តែភូមិខ្ញុំមានអី ភូមិខ្ញុំទៅដុះប្រធានភូមិវាសិស្ស ទើបសឹក ក្មាកូនអ្នកក្រគេឲ្យធ្វើប្រធានភូមិ ហើយស្ងាត់ៗខ្ញុំទៅយប់យកបាយស្រាក់មក ព្រោះសិស្ស ហើយមួយទៀតវាចេះ ប្រធានភូមិស្លាប់មនុស្សចាស់ ព្រោះប្រធានភូមិទាំងអស់ហ្នឹងសុទ្ធតែមកស៊ីឈ្នួលច្រូត ស៊ីឈ្នួលស្ទូងក្នុងភូមិហ្នឹង វាធ្លាប់តែស្លាប់តាំងពីណាណីមក ដល់ឡើងធ្វើប្រធានភូមិក៏អត់ហ៊ាននេះ អីចឹងទុកស្រូវក៏មិនខូច ធ្វើអីក៏មិនខូច ហើយមួយទៀតខាងលើប្រាប់មកត្រូវទុកប៉ុន្មានក្នុងឆ្នាំ ហើយខ្វះប៉ុន្មានឲ្យផ្សំជាមួយដំឡូងមី ហើយអ្នកដែលមិនយល់ចេះតែយកឈ្មោះ ។

ដានី៖ តែជំនាន់ហ្នឹងអ្នកដែលជាប្រធានភូមិ ប្រធានឃុំគាត់ហូបបាយផ្សេង ហើយប្រជាជនហូបបាយផ្សេង?

នៅ៖ អាហ្នឹងមិនទម្លាប់បានទេ មិនចូលចំណោមហ្នឹងទេ ខ្ញុំទៅលេងរឿងផ្សេង ប៉ុន្តែនៅត្រពាំងធំសហករណ៍នៅវត្តជួនទុកបាយនៅសហករណ៍ គេថាភ្ញៀវថ្មីយើងម៉េចដឹង យើងមានបានទៅនៅយូរណា ។

ដានី៖ ភ្ញៀវទៅលេងហូបបាយនៅសហករណ៍ យើងបានហូបគ្រប់គ្រាន់?

នៅ៖ មានអី តែមួយភូមិខ្ញុំហ្នឹង មួយឃុំហ្នឹងអត់អីទេ គេស្លាប់មនុស្សចាស់ ។

ដានី៖ ពេលដែលលោកតាធ្វើការនៅមន្ទីរ នៅភូមិភាគ ហូបចុកយ៉ាងម៉េចទៅ មួយថ្ងៃប៉ុន្មានពេល ហើយមួយពេលយើងហូបប៉ុន្មាន?

នៅ៖ តាមធម្មតាហ្នឹង អត់មានកំណត់ដាក់អីចឹងទេ តែកន្លែងហ្នឹងគ្នាតិច ដើងវែង ជួនដឹកនេះដឹកនោះទៅបាត់ដំបង មកវិញក្រូចពោធិ៍សាត់ ជួនទៅតាកែវ កំពត មកវិញដូង ដឹកទៅទាំងឡានហើយដាក់កំដរដៃមកវិញហើយ មុនដំបូងគ្នា៣០នាក់មានអ៊ីអី ។

ដានី៖ អីចឹងហូបបរិបូរណ៍ អត់ខ្វះខាត?

នៅ៖ មានអី ។

ដានី៖ យើងទៅកន្លែងមានក្រូច មានដូង យកមកយើងហូប?

នៅ៖	គេដាក់តាមឡានមកព្រោះដឹកទៅទាំងឡានៗនោះដាក់មក កន្លែងគ្នាតិចអត់អីទេ ហើយមួយទៀតមេគ្រប់គ្រងមិនឆ្វេង គេហៅឆ្វេង ឆ្វេងពេក ។

ដានី៖	មេគ្រប់គ្រងឆ្វេងពេក?

នៅ៖	ឆ្វេងពេក ។

ដានី៖	មេគ្រប់គ្រងណាដែលថាឆ្វេងពេក?

នៅ៖	ហ្នឹងកន្លែងណាដែលគ្រោះថ្នាក់ខ្លាំង ។

ដានី៖	បានន័យថាអ្នកគ្រប់គ្រងតាមមូលដ្ឋានហ្នឹង បើមេដឹកនាំឆ្វេងពេកធ្វើឲ្យគ្រោះថ្នាក់?

នៅ៖	ហ្នឹងហើយវាគ្រោះថ្នាក់ហើយ ឥឡូវយើងចេះ ខេត្តបាត់ដំបង និយាយពីខេត្តបាត់ដំបងអាហ្នឹងយើងនិយាយតាមយើងធ្លាប់ដឹងពីដើមមក មួយកម្ពុជាដែលលក់ស្រូវចេញគឺខេត្តបាត់ដំបង ហេតុអីពាឆ្នាំអត់បាយ ។

ដានី៖	មូលហេតុអី?

នៅ៖	មូលហេតុអីយើងមិនដឹងទេ ប៉ុន្តែដែលចប់ហើយសព្វគ្រប់ មានដល់ថ្នាក់មាស អាហ្នឹងយើងយកការណ៍តាមក្មេងទេ ថ្នាំពេទ្យដឹកចាក់ទន្លេសាប មានអីចឹងអាហ្នឹងក្មេងវានិយាយ វាឆ្ងល់ដែរម៉េចយកថ្នាំពេទ្យដឹកចាក់ដាក់ទន្លេសាប ហើយក្រណាត់ហេតុអីបានជាដាស៊ី? ១០០

ដានី៖	ឆ្នាំណា?

នៅ៖	អាហ្នឹងរវាង៧៦-៧៧ មិនច្បាស់ទេតែរវាងប៉ុណ្ណឹង តែអានេះចប់ហើយដែលយើងសរុបវាលែងនេះហើយ សរុបជួបគ្នា យើងសួរកាលហ្នឹងម៉េចៗ ។

ដានី៖	កម្មាភិបាលខាងណាដែលដឹកថ្នាំពេទ្យ ដឹកក្រណាត់?

នៅ៖	ហ្នឹងខាងមួយជួរបាត់ដំបង ។

ដានី៖	តែកាលហ្នឹងវាមានកម្មាភិបាល២ ។

នៅ៖	អាហ្នឹងយើងសួរក្មេងទេ យើងមិនបានដឹងទេ ហេតុអីនៅខាងហ្នឹងមានក្មេងយកទៅលេងជួបក្មេងធ្វើការនៅហ្នឹង ក្មេងមិនដាផ្លូវការ ។

ដានី៖	កាលហ្នឹងតារៀបការនៅ? មានប្រពន្ធនៅ?

នៅ៖	ខ្ញុំមាន៧៧ហ្នឹង ។

ដានី៖	ឆ្នាំ៧៧បានលោកតារៀបការ?

នៅ៖	ហ្នឹងហើយ ។

ដានីៈ ពេលហ្នឹង ពេលលោកតាកាន់ពីខាងដឹកជញ្ជូនទៅភូមិភាគ បន្ទាប់ពីនៅជាមួយ តាម៉ុក ចាប់ផ្ដើមមានតួនាទីជាអ្នកទទួលដឹកជញ្ជូន ចាប់ពីឆ្នាំណា?

នៅៈ ពី៧៦ ដើម៧៦ ។

ដានីៈ ដើមឆ្នាំ៧៦ទទួលជាខាងដឹកជញ្ជូន?

នៅៈ ចូល គ្រាន់តែគាត់ហៅទៅ មិនទាន់ទទួលមែនទែនទេ គាត់ហៅទៅដើម៧៦ ចុង៧៥ ខ្ញុំសឹកបានបន្តិច ។

ដានីៈ ដល់ពេលឆ្នាំ៧៧ ខែប៉ុន្មានលោកតារៀបការ?

នៅៈ អត់បានចាំខែទេ ។

ដានីៈ ដូចជាពេលហ្នឹងខែ បើរដូវវិញរដូវអី?

នៅៈ ដល់នេះទៅកូន៧៩កើតបាន៣ខែ ខ្ញុំច្រើនតែនិយាយថាបងខ្ញុំ៣ខែកូនខ្ញុំ ។

ដានីៈ កូនបងគេ?

នៅៈ ហ្នឹងឯង ។

ដានីៈ ហើយលោកតារៀបបានប៉ុន្មានបានកូន?

នៅៈ ចុង៧៧ មក៧៨ ដល់៧៩កូនកើតបាន៣ខែ ។

ដានីៈ ការហើយមានកូនភ្លាម?

នៅៈ ហ្នឹងហើយបែបមិនយូរទេ ។

ដានីៈ កាលហ្នឹងយ៉ាងម៉េចគ្រួសារលោកតាគាត់ធ្វើអីដែរ? ហើយម៉េចបានជួបគ្នា?

នៅៈ នៅខាងកាត់ដេរភូមិភាគ ហើយតា ហ្នឹងគាត់ចេះតែយកទៅផ្គុំដាក់ ។

ដានីៈ តាម៉ុក គាត់ផ្គុំឲ្យ ។

នៅៈ ហ្នឹងហើយ ។

ដានីៈ ប្រពន្ធលោកតាគាត់អ្នកស្រុកកំណើតនៅណា?

នៅៈ នៅតាកែវដែរ ។

ដានីៈ នៅតាកែវ នៅណាទៅ?

នៅៈ នៅព្រៃសណ្ដែក ល្វាព្រៃសណ្ដែក ។

ដានីៈ នៅភូមិអី?

នៅៈ ភូមិត្រពាំងលើក ។

ដានីៈ ឃុំព្រៃសណ្ដែក?

នោះ	ហ្នឹងហើយ អត់ទេ។

ដានី:	យុំអីហ្នឹង?

នោះ	យុំស្ពីចេះ ខាងកើតផ្សារល្វាហ្នឹង។

ដានី:	ស្រុកអីហ្នឹង? ស្រុកទ្រាំង

នោះ	ហ្នឹងទ្រាំង។

ដានី:	ប្រពន្ធលោកតាគាត់ឈ្មោះអីដែរ?

នោះ	អឿន។

ដានី:	អី អឿន?

នោះ	ងិន អឿន។

ដានី:	ហើយកាលលោកតារៀបការ លោកតាអាយុប៉ុន្មាន?

នោះ	៤៤។

ដានី:	កាលហ្នឹងគ្រួសារលោកតាគាត់អាយុប៉ុន្មានទៅ?

នោះ	ខ្ទង់២៧។ ឥឡូវខំសួរប្រវត្តិច្រើនម៉្លេះ ធ្វើប្រវត្តិសាស្រ្ត។

ដានី:	បន្ទាប់ពី៧៩ទៅបានដល់ ឥឡូវនេះអត់ទាន់ដល់ទេ។ បន្ទាប់ពីលោកតានៅតាកែវ។

នោះ	មានន័យនយោបាយរករឿងតែមនុស្សម្នាក់ទេ ឬប្រវត្តិកម្ពុជា?

ដានី:	អត់ទេលោកតា ដោយសារប្រវត្តិហូរហែរបន្តៗមក។ លោកតានៅតាកែវហ្នឹងដល់ឆ្នាំណាបានចេញពីកន្លែងដីកជញ្ជូន?

នោះ	៧៩ចេញពីភ្នំពេញមក។

ដានី:	អីចឹងនៅខាងដីកជញ្ជូនរហូតដល់៧៩ហ្នឹងតែម្តង?

នោះ	៧៩។

ដានី:	អីចឹងពេលដែល៧៩ ពេលដែលយួនចូលមកហ្នឹង យ៉ាងម៉េចទៀតទៅព្រឹត្តិការណ៍យ៉ាងម៉េច?

នោះ	មានអីនាំគ្នារត់ចេញទាំងយប់ ទុកឥវ៉ាន់ចោលពេញភ្នំពេញ។

ដានី:	បានន័យថាពេលដែលយួនចូលយើងចេញពីតាកែវ មកភ្នំពេញទាំងអស់គ្នា?

នោះ	អត់ទេ នៅភ្នំពេញ ខ្ញុំនៅភ្នំពេញ ប្រពន្ធកូននៅតាកែវ។

ដានី:	ខ្ញុំអត់ទាន់យល់ មុិញលោកតាមានប្រសាសន៍ថាលោកតានៅខាងដឹកជញ្ជូននៅភូមិភាគ?

នោះ	ភូមិភាគតែប្រចាំនៅភ្នំពេញ។

ដានី:	ភូមិភាគប្រចាំនៅភ្នំពេញ?

នៅ:	ហ្នឹងហើយ ។

ដានី:	អ្នកចែកឥវ៉ាន់ឲ្យទៅខាងភូមិភាគ តែលោកតាទទួលខាង?

នៅ:	ប្រចាំនៅភ្នំពេញ ។

ដានី:	ប្រចាំនៅភ្នំពេញ ទទួលភូមិភាគនីរតី?

នៅ:	យើងទទួលមកនៅជិតហ្នឹងទទួលទៅ ចាំដឹក ។

ដានី:	ដឹកទៅចែកនៅខាងនីរតី?

នៅ:	តាមខេត្ត ។

ដានី:	ដល់ពេលយួនចូលមកយ៉ាងម៉េច ជួបជុំប្រពន្ធកូននៅភ្នំពេញបានរត់?

នៅ:	កូនវាឈឺយកមកពេទ្យ ដល់បានមូលគ្នា ។

ដានី:	យ៉ាងម៉េចទៀតព្រឹត្តិការណ៍ពេលដែលយួនចូល?

នៅ:	មានអីខាងលើរត់អស់ហើយ នៅខាងក្រោមចេះតែនាំគ្នា ខាងលើបញ្ជាថាមើលតែនេះនាំគ្នាដុតប្រេងចោលទៅ ។

ដានី:	ដុតប្រេង?

នៅ:	ដុតប្រេងកុំទុកឲ្យសល់ ហើយប៉ុន្តែមួយយប់ទល់ភ្លឺអ្នកភ្នំពេញដើរបានត្រឹមផ្លូវបំបែកចោមចៅហ្នឹងទេ ចុះដញ្ជូនឥវ៉ាន់ ហើយខ្ញុំមកមុនមកនៅជិតផ្លូវរទេះភ្លើង ហើយក្មេងៗវាទៅមក

ដានី:	កាលហ្នឹងកូនលោកតាទើបបាន៣ខែ?

នៅ:	៣ខែ ដល់នេះចេះទៅមកៗ ដល់លឺសូរប៉ឹងៗហុយផ្សែងទ្រលោមបានទៅតាមកំពង់ត្រាំមានទៅតាមផ្លូវជាតិលេខ៤ណា៎ ។

ដានី:	មកផ្លូវលេខ៣វិញ?

នៅ:	អត់ទេ អាផ្លូវកំពង់ត្រាំក្បែរផ្លូវលេខ៤ បានមកដល់ជិតត្រែងត្រយឹងបានឆ្លងកាត់ហ្នឹងទៅហួស ។

បូលី:	ហួសបាត់ដឹងទៀត ។

នៅ:	ទៅជិតគិរីរម្យ ហួសខេត្តបន្ទិច ឆ្លងកាត់ផ្លូវលេខ៤ទៅជើង ។

ដានី:	ហើយម៉េចទៀតទៅ?

នៅ:	មានអីចេះតែទៅ យូរទៅអស់ឡាន អត់បាយស៊ីក្រហាយទឹកស្លាប់គ្នាចង់អស់មានអី ក្មួយប៉ុន្មានក៏ស្លាប់ ម្តាយក៏ស្លាប់ ដើរចុះ ដើរឡើង ឡើងភ្នំក្រវាញ ឡើងចុះៗ១៧ថ្ងៃ ។

ដានីៈ លោកតាអាចរៀបរាប់ថាពេលតាមផ្លូវយើងដើរទៅ ពេលហ្នឹងចេញទៅគ្នាប៉ុន្មាននាក់ក្រុមគ្រួសារលោកតា ហើយមានស្បៀងយ៉ាងម៉េចពេលដែលយើងធ្វើដំណើរ?

នោះៈ ធ្វើដំណើររត់ចោលឡានមានអី ទៅត្រពាំងផ្លូវហ្នឹងរាប់ខែដែរ ហើយបែកចេញពីហ្នឹងទៅហ្នឹងរត់ចោលឡានហើយ ឥវ៉ាន់អង្ករមួយខែ ដល់ខែ៩ ៧៩ បានយួនចាប់បាន។

ដានីៈ ខែ១ ៧៩?

នោះៈ ខែ៩ ៧៩។

ដានីៈ ខែ៩ ៧៩យួនចាប់លោកតាបាន?

នោះៈ ចាប់បាន។

ដានីៈ ចាប់បានប៉ុន្មាននាក់?

នោះៈ គ្នាខ្ញុំ៣នាក់ ម៉ែ កូន ឪ ហើយក្មួយមួយ។

ដានីៈ លោកតា ប្រពន្ធលោកតា ហើយកូន។

នោះៈ កូនតូចហ្នឹងហើយនិងក្មួយមួយ។

ដានីៈ យួនចាប់បាននៅណា?

នោះៈ នៅឃុំប៉ែន ព្រែកត្រឡាច។

ដានីៈ នៅណា?

នោះៈ នៅឃុំប៉ែន ព្រែកត្រឡាច នៅស្រុកម៉ោង។

ដានីៈ ភូមិប៉ែនព្រែកត្រឡាច ក្នុងស្រុកម៉ោង។ ហើយពេលហ្នឹងយ៉ាងម៉េចបានយួនចាប់លោកតាបាន?

នោះៈ អីមិនបានបើអស់អីស៊ីហើយ ទៅលែងរួច គាកែវមានអីស៊ីទាល់តែទៅព្រៃជ្រៅ ដល់ឯងអត់អីស៊ីមិនមកនៅក្បែរភូមិ។

ដានីៈ កាលហ្នឹងលោកតាទៅដាច់ពីខាង កាលហ្នឹងយើងកម្មាភិបាលខ្មែរក្រហមទៅពីភ្នំពេញជាមួយគ្នា។

នោះៈ ទៅគេទៅព្រំដែនអស់ទៅ។

ដានីៈ លោកតាអត់ទៅជាមួយគេទេ?

នោះៈ ទៅម៉េចទាន់។

ដានីៈ អត់ទៅជាមួយ តាម៉ុក?

នោះ	ទៅម៉េចទាន់ ហ្នឹងយើងផ្សេង គេខាងលើៗគេចេញបាត់យូរហើយ តែយើងមានឡានដែរ គេប្រាប់ឲ្យយើងរត់ទៅព្រំដែនដែរ ហើយដល់អស់ឡានទៅបានអី ។

ដានី៖	កាលហ្នឹងលោកតាមានរបបឡានដិះដែរ?

នោះ	ឡានដឹកជញ្ជូនឥវ៉ាន់ហ្នឹង ហើយបានប៉ុន្មានទៅបន្តិចគេស្កាត់បានមិនចប់ ។

ដានី៖	ឡានម៉ាកអី?

នោះ	ដូចHINO ពួកឡានធំៗ ។

ដានី៖	លោកតាបើកខ្លួនឯង?

នោះ	មិនចេះបើកទេ ។

ដានី៖	ពេលយើងរត់ទៅមានតែគុងបើកឲ្យដែរ?

នោះ	ទៅមានទាំងអស់ ជំនាន់ហ្នឹងមានទាំងអស់ ។

ដានី៖	ពេលដែលយួនចាប់បានយ៉ាងម៉េចទៅ លោកតាអាចរៀបរាប់រយៈពេលដែលយួនចាប់បាន

នោះ	សួរស្រុកភូមិនៅណា យើងប្រាប់ថានៅស្វាយដូនកែវ ។

ដានី៖	ពេលដែលយួនចាប់បានគ្រាន់តែសួរស្រុកទេសលោកតា? យួនអត់មានធ្វើបាបលោកតាទេ?

នោះ	បាញ់ ។

ដានី៖	បាញ់ត្រូវត្រង់ណាទៅ?

នោះ	ខ្ញុំមុនដំបូងថាគេបាញ់បង្អុសបានអត់ត្រូវ យើងនៅដើងដំបូក គេនៅកំពូលដំបូកហើយអែបនឹងដើមឈើ ហើយយើងកំពុងព័ទ្ធស៊ុក្លត ដេកលើភក់ បាញ់មកបើកុំតែឃើញអំបែង យើងមិនជឿថាគេបាញ់មែនទែនទេ ។

ដានី៖	គ្រាប់អី?

នោះ	គ្រាប់អំបែង៧៩ ទឹង តែប៉ះមែកឈើបែករោយពីលើ តែពួកទាហានគេថារោយពីលើហ្នឹងល្អ តែខ្ញុំនិយាយប្រាប់គេថាគេបាញ់បង្អុស តែគិតមើលបើបាញ់ខុសម៉េចមិនដាក់គ្រាប់អំបែង តែដាក់៧៩ ។

ដានី៖	តែក្នុងចំណោមក្នុងហ្វូងដែលលោកតាមានប្រសាសន៍មិញ លោកតា ប្រពន្ធលោកតា កូន ហើយក្មួយអត់មានពីណាម្នាក់ត្រូវរបួសទេ?

នោះ	អត់ ត្រូវក្មួយមួយ ទង្គិច៧៩ ។

ដានី៖	បន្ទាប់ពីហ្នឹងហើយគេចាប់លោកតាហើយ គេយ៉ាងម៉េច?

នៅៈ គេនាំទៅកន្លែងមេគេ យកទៅចោលស្វាយដូនកែវ ស្រុកនៅណាឲ្យទៅហ្នឹង ។

ដានីៈ គេអត់មានសួរចំលើយ គេអត់មានធ្វើទារុណកម្មលោកតាទេ?

នៅៈ អត់ទេ បើយើងជិតងាប់ហើយ បែបគេខ្ទើមគេមិនដឹង សក់ខានកាត់៥ខែហើយ ។

ដានីៈ ហើយយ៉ាងម៉េចទៅពេលដែលគេដឹក ដឹកតាមរយៈអីទៅ?

នៅៈ ដើររហូតដល់ស្វាយដូនកែវ ដើរជាមួយគេមួយចំហៀង ។

ដានីៈ ហើយហូបចុកយ៉ាងម៉េចទៅពេលដែលយួនចាប់បានហើយ?

នៅៈ បាយគេសល់គេឲ្យស៊ីខ្លះដែរ សល់ពីទាហានគេ ។

ដានីៈ សល់ពីទាហានគេឲ្យបាយហូបខ្លះដែរ?

នៅៈ ឲ្យហូប ។

ដានីៈ បាយហូបហ្នឹងយ៉ាងម៉េច? គេឲ្យហូបឆ្អែតដែរ ឬក៏ហូប?

នៅៈ សល់ពីគេតិចតួច គេយកមកហើយឃើញមានកូនតូច មិនឲ្យជាដូវការមែនទែនទេ នៅសល់ ។

ដានីៈ ក្រៅពីគ្រួសារលោកតាគ្នា៤នាក់ដែលរៀបរាប់មិញ មានអ្នកផ្សេងគេចាប់បានដែលអត់?

នៅៈ ពេលហ្នឹង?

ដានីៈ គេចាប់បានបញ្ជូនមកស្វាយដូនកែវ?

នៅៈ ពេលហ្នឹងតែខ្ញុំប៉ុណ្ណឹងទេ ដល់យើងសរុបរឿងសាច់ញាតិយើងដែលគេនេះដែរ អាមួយប្អូនជីទួតមួយវារត់ជាមួយគ្នាហើយវាបែកគ្នា ក្មេងត្រូវរបួសម្តាយក៏ស្លាប់ ដល់ពេលគេឲ្យមកគាត់អត់មកគេបាញ់ផ្តប់ នៅសល់ក្មេងមួយបាននាំមក អាហ្នឹងក្មេងនៅត្រពាំងធំសព្វថ្ងៃក្មេងស្រី ។

ដានីៈ បាញ់ត្រូវ?

នៅៈ បាញ់ផ្តប់វានៅហ្នឹង ។

ដានីៈ អីចឹងលោកតាពេលដែលមកដល់ស្វាយដូនកែវ ហើយម៉េចទៀត?

នៅៈ ស្វាយដូនកែវនៅរកស៊ីហ្នឹងទៅ ។

ដានីៈ លោកតានៅរកស៊ីហ្នឹង?

នៅៈ ហ៊ឺ ។

ដានីៈ នៅរកស៊ីហ្នឹងយ៉ាងម៉េច លោកតាអាចរៀបរាប់តាមដំណាក់ៗ?

នៅៈ រកស៊ីកាត់ដេរ ហើយមានកូនចិន កាលហ្នឹងទាក់ទងជាមួយទាហានយកប្រេង ស៊ីបជីង ប្រុចមកភ្នំឆ័ត្រទៀត ។

ដានីៈ ឆ្នាំណាដែលលោកតារត់ពីស្វាយដូនកែវ មកភ្នំឆ័ត្រហ្នឹង?

នៅៈ ឆ្នាំ៨០ ។

ដានីៈ ម៉េចបានជាលោកតាមានបំណងចេញពីស្វាយដូនកែវមកភ្នំឆ័ត្រមូលហេតុអី លោកតាអាចរៀបរាប់កន្លែងហ្នឹង?

នៅៈ ឃើញពួកUNហ្នឹងគេសំបូរអង្ករ មានអ្នកដែលគេចេញចូលមក ។

ដានីៈ បានន័យថាខាងខ្មែរក្រហមគេចូលមកស្វាយដូនកែវដែរ?

នៅៈ អត់ទេ ពួកអ្នករកស៊ីព្រំដែន កាលហ្នឹងមិនពួកUNចិញ្ចឹម ។

ដានីៈ កាលជំនាន់ពួកអ្នករកស៊ីរត់ពន្ធទៅមកស្វាយឆ្នាំ៨០?

នៅៈ ហ្នឹងហើយ ។

ដានីៈ ពេលដែលលោកតានៅស្វាយដូនកែវ វាជួបផលវិបាកយ៉ាងម៉េច បានជាចង់មកខាងUN ចិញ្ចឹម? ឬលោកតាមានគំនិតអីដែលយើងមិនចូលចិត្តជាមួយយួនកាលហ្នឹង?

នៅៈ អាហ្នឹងយើងគិតហើយ អស់ដីហើយ មិនបាច់សួរអីច្រើនទេកាលហ្នឹង អស់ទឹក អស់ដី ។

ដានីៈ បានន័យថាយើងអស់ទឹក អស់ដីយួនចូលមកឈ្លានពានស្រុកយើង យើងអត់ចូលចិត្តទេ?

នៅៈ យើងនឹកឃើញថាទៅធ្វើអាចារ្យនៅស្រុកថៃទៅ ។

ដានីៈ ទាំងក្រុមក្រុមគ្រួសារលោកតា ចេញឆ្នាំ៨០ពីស្វាយដូនកែវ មកភ្នំឆ័ត្រ?

នៅៈ ហ្នឹងហើយ ។

ដានីៈ កាលហ្នឹងយ៉ាងម៉េចយើងមកតាមដំណើរធម្មតា ឬយើងលួចរត់ចេញមកពីស្វាយដូនកែវ?

នៅៈ យើងសុំច្បាប់គេ មករកស៊ីនៅស្វាយ ដល់ស្វាយហើយក៏ ចុះទៅមកហូរហែរពេញតែដី គេរត់ពន្ធគគ្រឹកគគ្រេង ។

ដានីៈ សុំច្បាប់ហ្នឹងសុំច្បាប់យួន ឬក៏សុំអាជ្ញាធរខ្មែរយើង?

នៅៈ ខ្មែរ ។

ដានីៈ ខ្មែរអាជ្ញាធរភូមិ ឬក៏យ៉ាងម៉េច?

នៅៈ បាទ ។

ដានីៈ សុំគេមករកស៊ី?

នៅៈ នៅស្វាយ ។

ដានី៖ ដល់ពេលតាមដំណាក់កាលយ៉ាងម៉េចទៅ លោកតាអាចជួយជំរាប?

នៅ៖ មានអីជិះម៉ូតូឌុប រ៉ឺម៉កម៉ូតូ ដល់នេះទៅឃើញពួកគេចពន្ធដើរជាមួយគ្នារហូត។

ដានី៖ ពេលណាដែលលោកតាមកដល់ភ្នំឆ័ត្រ? ពីស្វាយមកដល់ភ្នំឆ័ត្រ?

នៅ៖ ឆ្នាំ៨០ហ្នឹងហើយ។

ដានី៖ ឆ្នាំ៨០ដដែល តែប៉ុន្មានខែ?

នៅ៖ មានអីទៅយូរ យើងដេកផ្លូវ១យប់ ចេញពីស្វាយទៅភ្នំឆ័ត្រ។

ដានី៖ ខែប៉ុន្មានដែលលោកតាចេញពីស្វាយដូនកែវ?

នៅ៖ ខែដើមឆ្នាំមានភ្លៀង។

ដានី៖ ពេលដែលលោកតាមកដល់ភ្នំឆ័ត្រយ៉ាងម៉េចខ្លះទៀតទៅ? ដូចថាសភាពការណ៍យ៉ាងម៉េច លោកតាជួបប្រទះ?

នៅ៖ UNជួយគគ្រឹកគគ្រេង គ្រាន់តែថាទឹកដោះគោទាំងបាវៗ ទាំងការ៉ុងៗ ហើយថ្នាំពេទ្យគ្រប់គ្រាន់អត់មានខ្វះទេ ហើយខ្ញុំនៅហ្នឹងមានធ្វើអី ខ្ញុំដាំល្ពុងហើយអំពៅអត់មានធ្វើអី។

ដានី៖ នៅភ្នំឆ័ត្រហ្នឹងតែម្តង?

នៅ៖ ភ្នំឆ័ត្រមុខព្រួញភ្នំឆ័ត្រ តែខាងផ្នែកព្រៃមាន់។

ដានី៖ ចូលខាងព្រះនេត្រព្រះវិញ?

នៅ៖ បាទ។

ដានី៖ នៅភ្នំឆ័ត្ររយៈពេលប៉ុន្មានបានចេញពីភ្នំឆ័ត្រ?

នៅ៖ នៅ៣ឆ្នាំ វិវទៀតទៅម៉ាឡៃ។

ដានី៖ ៣ឆ្នាំ អីចឹងដល់ឆ្នាំ៨៣?

នៅ៖ ៨៣។

ដានី៖ វិវគ្នានៅភ្នំឆ័ត្រហើយ ចេញពីភ្នំឆ័ត្រមកនៅម៉ាឡៃវិញ?

នៅ៖ គេដឹកចេញមកនៅខាវអ៊ីដាង។

ដានី៖ លោកតាអត់ទៅនៅខាវអ៊ីដាងទេ មកនៅម៉ាឡៃវិញ?

នៅ៖ ទៅខាវអ៊ីដាងចេញពីខាវអ៊ីដាងទៅម៉ាឡៃ។

ដានី៖ លោកតាអាចរៀបរាប់ថាចេញពីភ្នំឆ័ត្រទៅនៅខាវអ៊ីដាងបានប៉ុន្មាន។

នោះ	មិនមែនខាវអ៊ីដាំងគេ គេហៅណេងមាំង វាជិតខាវអ៊ីដាង រៀបចំជំរុំកន្លែងថ្មី ហើយបានដឹកចេញពីហ្នឹង ហើយនៅហ្នឹងចោរប្លន់បាញ់អ្នកស្រុកស្លាប់ បានដឹកចេញ អ្នកណាចង់ទៅណាទៅហ្នឹង ទៅកំពង់អំពិល អ្នកណាទៅម៉ាឡៃៗ ចង់ទៅណាគេជូនទៅហ្នឹង ។

ដានី:	លោកតាមានប្រសាសន៍មិញថាមានចោរប្លន់ ចោរណា ខ្មែរយើងប្លន់ ឬថៃ?

នោះ	ខ្មែរយើងផងអីផង ។

ដានី:	ប្លន់នៅក្នុងដីខ្មែរ ឬដីថៃ?

នោះ	ដីខ្មែរ ។

ដានី:	ខ្មែរយើងហ្នឹង?

នោះ	ហ្នឹងហើយ ។

ដានី:	ខាងទាហាន?

នោះ	ថ្ងៃលេងល្បែងក្នុងជំរុំ យប់ឡើងប្លន់ ។

ដានី:	ក្នាងងហ្នឹង?

នោះ	ដឹងអីយើងបាន់មើលទៅ ប្រហែលជាក្នាងង ។

ដានី:	ខាងកងទ័ពខ្មែរក្រហមក្នាងង?

នោះ	មិនដឹងណាខ្លះទេ ប៉ុន្តែកន្លែងហ្នឹងចំរុះ ។

ដានី:	ចំរុះហ្នឹងមានអីខ្លះ? មានសមាសភាពខាងអីខ្លះ?

នោះ	ជំរុំចាស់ ជំរុំថ្មី ណងមាំង វាចំរុះគ្នា ។

ដានី:	លោកតាមានប្រសាសន៍ថាអ្នកណាចង់ទៅណា គេដឹកទៅណា កាលហ្នឹងលោកតាចង់មកម៉ាឡៃ?

នោះ	ចង់ហើយ ។

ដានី:	ហេតុអីបានជាលោកតាគិតថាចង់មកម៉ាឡៃ?

នោះ	ចុះមានរយៈខាងហ្នឹង បើខាងបឹងក្រពើមានរយៈណា ។

ដានី:	កាលហ្នឹងខាងបឹងក្រពើពីណាគេអ្នកគ្រប់គ្រង?

នោះ	អត់ដឹងទេ លឺគេហៅ ។

ដានី:	ខាងម៉ាឡៃម៉េចបានមានរយៈ?

នោះ	វានៅអគ្គភាពខ្មែរក្រហម យើងពួកខ្មែរក្រហមយើងមិនស្គាល់ ។

ដានី:	កាលហ្នឹងពីណាគ្រប់គ្រងនៅម៉ាឡៃ?

នោះ	ជុំរុំធំ តាអៀង សារី ហ្នឹង ។

ដានី៖	អៀង សារី គាត់នៅម៉ាឡៃ?

នោះ	ហ្នឹងហើយ ។

ដានី៖	លោកតាមកនៅម៉ាឡៃបានរយៈពេលប៉ុន្មានទៅ?

នោះ	នៅមិនយូរទេជិតមួយឆ្នាំ មានគេមកនេះក៏មកនេះដែរមក ។

ដានី៖	យ៉ាងម៉េចបានលោកតាផ្លាស់ទៀតហើយ ដូចថាទៅដល់កន្លែងម៉ាឡៃហ្នឹង ខាងខ្មែរក្រហម តាអៀង សារី គាត់គ្រប់គ្រងនៅហ្នឹង ហើយនៅបានមួយឆ្នាំលោកតាផ្លាស់មកខាង?

នោះ	ឥឡូវហ្នឹងសួរដេញហ្នឹងសួរចង់ដឹងម៉េចខ្លះ បើខ្ញុំនៅជាមួយខ្មែរក្រហមចង់ដេញម៉េចទៀត អាហ្នឹងប្រាប់ចំណងដើងហើយស្រេចហើយ នៅអីចឹងគេស្គាល់ ទៅនៅកន្លែងផ្សេងយ៉ាងម៉េច អីចឹងទៅនៅកន្លែងគេស្គាល់ និយាយឲ្យខ្លី អីចឹងមិនបាច់ដេញអីច្រើនទេ ។ បើចង់ដឹងថាខ្ញុំកុំមុយនីស្ត ឬមិនកុំមុយនីស្តអាហ្នឹងរឿងផ្សេង ។

ដានី៖	ត្រឹមត្រូវលោកតា លោកតាមានប្រសាសន៍មិញថា ។

នោះ	អ្នកកុំមុយនីស្តអ្នកសាសនា ចង់ដឹងៗប៉ុណ្ណឹង តែចូលក្នុងហ្នឹងហើយ វាមានគ្នា មកភ្នំឆ័ត្រ មកនេះវាមានគ្នានេះ ទៅនោះវាមាននោះ ទៅនៅកន្លែងផ្សេងវារឿង អាហ្នឹងអីចឹង មិនបាច់ចង់ដឹងអីច្រើន ។

បូលី៖	នៅម៉ាឡៃមួយឆ្នាំបានបកមក?

នោះ	មកនេះ ។

ដានី៖	បាទ មកម៉ាឡៃមួយឆ្នាំលោកតាបកមកនេះ ដោយសារលោកតាស្គាល់គ្នាម៉េចបានមកខាងនេះវិញ?

នោះ	បើនិយាយនេះទៅ តាម៉ុក គាត់ហៅ ។

ដានី៖	ខ្ញុំចង់ដឹងហ្នឹងដោយសារលោកតាមានខ្សែ មានគ្នា ពីណាគេអ្នកហៅលោកតាមកចង់ដឹងអីចឹង?

នោះ	មិនជាអស្ចារ្យប៉ុន្មានទេរឿងហៅ ខ្ញុំប្រាប់ហើយអស់ហើយ ហៅហ្នឹងឲ្យមកបង្រៀនក្មេងនៅក្បែរវត្តហ្នឹង មិនមែនឲ្យមកកាន់កាំភ្លើងទេ ។

ដានី៖	ឆ្នាំហ្នឹងឆ្នាំប៉ែតប៉ុន្មានទៅដែលគាត់ហៅមក?

នោះ	អាច៨៣ ។

បូលី៖	មកណាវិញ?

នៅៈ	មកនៅភ្នំដងរែក ហ្នឹងហៅមកបង្រៀនក្មេងទេ ។

ដានីៈ	ហ្នឹងគេហៅទិសអីទៅ?

នៅៈ	អាហ្នឹងខាងភ្នំដងរែក ខាងខត្តរ ។

ដានីៈ	តាម៉ុក គាត់គ្រប់គ្រងនៅខាងខត្តរហ្នឹង?

នៅៈ	គាត់មកនៅខាងហ្នឹងហើយ ។

ដានីៈ	អីចឹងគោលបំណងរបស់គាត់ដំបូង គាត់ហៅលោកតាឲ្យមកបង្រៀនក្មេង?

នៅៈ	មកបង្រៀនក្មេង ។

ដានីៈ	កាលហ្នឹងលោកតាដឹងពីគោលបំណងយ៉ាងម៉េច កាលហ្នឹងយើងបង្កើតជាសាលាបង្រៀនក្មេង?

នៅៈ	បង្កើតសាលានៅភ្នំដងរែកហ្នឹង បង្កើតមានប្រឡងចូលថ្នាក់ទី៦ ពួកហ្នឹងមកដល់គឺរៀបចំហើយ គ្រូចាស់ៗគ្រូហុមមីស្យុង គ្រូកំពង់កន្ទួតអីមក ។

ដានីៈ	យើងមានបង្កើតជាសាលា មានជាថ្នាក់ មានជាគ្រូ ជានាយក នាយករង?

នៅៈ	មានអី បើគ្រូកំពង់កន្ទួត គ្រូហុមមីស្យុង មកដល់រៀបចំហើយ គរុកោសល្យគ្រូចាស់ៗប្រមូលគ្នាមកចាំប៉ុន្មានអីប៉ុន្មានយកមក ហើយចុងក្រោយមកដល់នេះគាត់យកគ្រូថៃមកជួយ ។

ដានីៈ	ជួយគ្រូថៃមកជួយបង្រៀនខ្មែរ?

នៅៈ	ជួយបង្ហាត់បច្ចេកទេស ៣០ឆ្នាំវាដើរមិនទាន់សកលលោក ពួកកំពង់អំពិលយូរហើយ បានយកបច្ចេកទេសសម័យថ្មីយកមក យកមកជួយ ខ្ញុំក៏នៅហ្នឹងដែរ គាត់ថារៀបចំឲ្យបានប្រឡងឌីប្លូមនៅហ្នឹង មានបានណា កំពុងតែរៀបចំដំណើរការវៃគ្នាក្ដីងបិទសាលាទៅ ។

ដានីៈ	អីចឹងយើងចាប់ផ្ដើមមានសាលារៀនពីឆ្នាំ៨៣មក?

នៅៈ	៨៣នៅលើ ហើយទៅដំរុំក៏អីចឹងដែរពួកគ្រូដែរនៅនេះហ្នឹង ពួកUNគេទំនុកបំរុងទៀត ។

ដានីៈ	កាលហ្នឹងគំនិតផ្ដួចផ្ដើមដែលមានសាលាបង្រៀនកូនសិស្សហ្នឹងពី តាម៉ុក ឬក៏មានពីណា?

នៅៈ	អាហ្នឹងមានពីលើមកគេថាឈប់ធ្វើកុំមុយនីស្ដហើយ មិនប្រកាសលុបបក្ស សភាពការណ៍សកលលោកវាអំណោយផល បង្កើតតាំងពីខ្ញុំនៅភ្នំឆ័ត្រប្រកាសលុបបក្សលែងធ្វើកុំមុយនីស្ដហើយ អីចឹងរៀបចំសិក្សាធិការតាមដំណើរ ឲ្យទៅជាពហុភាគី ទៅជាសេរីហើយមានគណបក្សច្រើនហើយ ចាប់កំណើតពីហ្នឹងមក ហើយការប្រជុំ ការរៀនសូត្រក៏ប្រកាស

អ៊ីចឹង ជាមហាអំណាចពិភពលោកប្រញាប់យផលប្រយោជន៍នៅកម្ពុជា គេដណ្ដើមគ្នាអ៊ីចឹង យើងធ្វើកុំមុយនីស្ដមិនបានទេ អាហ្នឹងឯកសារចេញអ៊ីចឹងហើយ ។

ដានី: ដំបូងដែលយើងបើកសាលា កាលហ្នឹងកូនសិស្សចូលរៀនប្រហែលជាប៉ុន្មាននាក់?

នោ: មិនចាំទេ តែច្រើនគ្រូ៨-១០នាក់ ។

ដានី: ប៉ុន្តែដល់ពេលលោកតាជាអ្នកគ្រប់គ្រងគ្រូទាំងអស់ហ្នឹង?

នោ: មានគណៈកម្មការ ។

ដានី: ប៉ុន្មាននាក់ទៅគណៈកម្មការ?

នោ: គណៈកម្មការ៤-៥នាក់ គណៈកម្មការខាងលើតែ៣នាក់ ឥឡូវ២នាក់នោះស្លាប់ហើយ នៅសល់តែខ្ញុំ ។

ដានី: ពីណាខ្លះ?

នោ: ហ្នឹងគេទៅស្រុកហើយ ទៅស្លាប់នៅស្រុក ហើយមួយទៀតខ្ញុំថាចោរបាញ់ហ្នឹង បងលាវ ។

ដានី: លោកតា, តាលាវ ហើយពីណាមួយទៀត?

នោ: អឿន គាត់ចូលទៅក្នុងបង្រៀនអនុវិទ្យាល័យនៅអគ្គរការហើយស្លាប់បាត់ហើយ ។

ដានី: ហើយយើងបង្រៀនយើងមានចាប់ពីថ្នាក់ទី១ ទី៣ ទី៥?

នោ: អាហ្នឹងមាន ស្រាវជ្រាវមើលសៀវភៅកម្ពុជាប្រជាធិបតេយ្យ កុមារដ្ឋានអីមាន ។

ដានី: លោកតាមាននៅសេសសល់សៀវភៅហ្នឹងដែលអត់?

នោ: មានដែល តែមិនដឹងទុកនៅណាខ្លះ ចេះតែទុកនៅគរៗគ្នា ។

ដានី: អ៊ីចឹងនៅផ្ទះលោកតាអាចនៅសល់សៀវភៅហ្នឹងដែរ?

នោ: អាចមានខ្លះដែរ សៀវភៅមួយខ្ញុំប្រែកម្មវិធីសិក្សាជាមួយថៃហ្នឹង ដល់នេះវើចុះវើឡើងរត់ចោល ចង់ទុកជាឯកសារដែរ តែចុះឡើងចោល ។

ដានី: អ៊ីចឹងកាលបង្រៀនហ្នឹងនៅលើភ្នំដងរែកតែម្ដង? មានធ្វើសាលា?

នោ: មានធ្វើសាលាត្រឹមត្រូវ ។

ដានី: បង្រៀនពីឆ្នាំណាដល់ឆ្នាំណាបានឈប់?

នោ: អាហ្នឹងហើយដែលខ្ញុំប្រាប់ថាខ្ញុំមិនមែនអ្នកប្រវត្តិសាស្ត្រ ខ្ញុំមិនបានជាកត់ ។

ដានី: ប្រហែលជាឆ្នាំ? ពេលហ្នឹងឈប់មុន ឬក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ៩១?

នោ: មែនទែនហើយពីហ្នឹងទៅ អន្តរជាតិប្រមូលទៅជំរុំ គេចទៅប្រាប់ កើតជំរុំអូរត្រាវបាននាំគ្នាទៅជំរុំ ដល់ប៉ុន្មាន កៅប៉ុន្មាន ពួកអង្គការអន្តរជាតិមកចុងក្រោយ ។

ដានី៖ ពួកអ៊ុនតាក់ដែលចូលមកបោះឆ្នោត?

នៅ៖ ហ្នឹងហើយ ។

ដានី៖ បោះឆ្នោតលើកទី១ឆ្នាំ៩៣ ។

នៅ៖ ហ្នឹងហើយ បានចេញមក នាំគ្នារៀបចំត្រៀមបោះឆ្នោត ដល់បោះឆ្នោតទទួលលោកខៀវ សំផន លោកណាទៅភ្នំពេញនាំគ្នាវិលរត់មកវិញ រត់មកវិញ ក្រោយគេវ៉ៃតទៀត ។

ដានី៖ លោកតាពេលដែលយើងចុះមកនៅអន្លង់វែងដំបូងគេឆ្នាំណាទៅ លោកតាចាំទេ? ដែលថាចុះពីលើភ្នំមកនៅអន្លង់វែង?

នៅ៖ ជំនាន់អ៊ុនតាក់ហ្នឹងមកនៅ ចេញពីជំរុំមកនៅ វ៉ៃគ្នាហ្នឹង ដល់អត់បាននេះឆេះផ្ទះមួយដុតចោល ទៅនៅស្រះឈូក មកវិញនៅផ្ទះនេះ ចោលអាផ្ទះនោះគេរុះយក មកធ្វើស្រែមែនទែនហើយអត់មានរវល់អីទេ ។

ដានី៖ ពេលដែលចុះមកហើយ កម្មវិធីបង្រៀនកូនសិស្សនៅតែបន្តរហូត ឬមានអាក់ខាន?

នៅ៖ បង្រៀនហើយ ក្រោយពីពេលវ៉ៃគ្នាដែលយកថៃមកជួយហ្នឹង អាហ្នឹងរៀនមែនទែន ដល់វ៉ៃទៅរត់ចោលសាលាបិទសាលា ។

ដានី៖ កាលហ្នឹងយើងរត់ចុះមកក្រោមនៅ ដែលមានថាយកថៃមក?

នៅ៖ ចុះមកហ្នឹង ជំនាន់អ៊ុនតាក់នឹកឃើញថាវាចប់ហើយ ។

ដានី៖ បង្រៀនសាលាដែល តាម៉ុក បង្កើតហ្នឹង?

នៅ៖ សាលាហ្នឹង ។

ដានី៖ ដល់ពេលវ៉ៃគ្នាបិទសាលារត់ចោល?

នៅ៖ បិទសាលារត់ ។

ដានី៖ យកថៃមកជួយហ្នឹង ជួយខាងបច្ចេកទេសខាង?

នៅ៖ បច្ចេកទេសសម័យថ្មី ព្រោះយើងចាស់បន្តិចហើយជាង៣០ឆ្នាំ មានគ្រូកំពង់កន្ទួត ហុមម៉ាស្យុងដែលតែចាស់បន្តិច ។

ដានី៖ ហើយលោកតាកាលហ្នឹងជានាយកសាលា ឬយ៉ាងម៉េច?

នៅ៖ អាហ្នឹងវាដូចជានាយក តែក្នុងគណៈកម្មការ ជួនគេផ្លាស់ប្តូរគ្នា ជួនខ្ញុំក៏ឡើងប្រធាន ផ្លាប់ប្តូរគ្នា តែអាហ្នឹងនៅក្នុងគណៈកម្មការ ។

ដានី៖ បើតាមលោកតាជាគណៈកម្មការក្នុងសាលាដែរ កាលហ្នឹងគោលបំណងដែលយើងបង្កើតសាលា ការបង្រៀនក្មេងៗក្នុងគោលបំណងអីទៅ?

នោះៈ អាហ្នឹងសួរដូចជាដេញហួសពេក បើគេឈប់ធ្វើកុំមុយនីស្ត រៀនវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ រៀនទូទៅដូចយើងសិក្សា ម៉េចហៅថាសកលលោក យកថៃៗមិនសេរី យើងឈប់ធ្វើកុំមុយនីស្តហើយ យើងកុំមុយនីស្តម៉េចទៅយកពួកសេរីមកជួយ អាហ្នឹងនិយាយឲ្យអស់មិនបាច់សួរអីច្រើនទេ រៀនហ្នឹងឲ្យស្របតាមដំណើរសកលលោក ព្រោះយើងលុបបក្សឈប់ធ្វើកុំមុយនីស្ត ដើម្បីរស់នៅជាមួយសកលលោក រស់នៅជាមួយគ្រប់ភាគីទាំងអស់ ។

បូលីៈ កាលហ្នឹងមានមេរៀនអីខ្លះលោកតា?

នោះៈ មេរៀនតែមិនបានច្រើន ព្រោះថ្នាក់ទី៥ គណិតសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ មិនទាន់អីធំដុំ ។

បូលីៈ បាន៣មុខវិជ្ជាទេ?

នោះៈ ហ្នឹងហើយ វិទ្យាសាស្ត្រធម្មជាតិ ។

បូលីៈ ប្រវត្តិយើងរៀនអីកាលហ្នឹង?

នោះៈ ប្រវត្តិហ្នឹងក៏អត់មានទៅឆ្ងាយដែរ អត់ទាន់ទៅវែងឆ្ងាយទេ ។

ដានីៈ អត់ទាន់ទៅវែងឆ្ងាយបានន័យថាយើងរៀនពី ចាប់ផ្តើមពីអីទៅ?

នោះៈ កាលហ្នឹងនិយាយឲ្យនេះទៅ រឿងប្រវត្តិល្មមទេ ខំគណិតសាស្ត្រ ផ្នែកវិជ្ជាផ្សេងៗច្រើន ក្មេងថ្នាក់ទី៥ មើលកូនខ្ញុំមួយវារៀនទី៤ ខ្ញុំយកទៅស្រុកខ្ញុំឲ្យចូលទី៦ ខំវិជ្ជាចាំបាច់ ។

ដានីៈ បើខាងអក្សរសាស្ត្រយើងរៀនច្រើនអត់?

នោះៈ អក្សរសាស្ត្រកាលហ្នឹងមិនទាន់មានទេ អក្សរសិល្ប៍មិនទាន់មានណាថ្នាក់ទី៥ ទៅដល់លើបានមាន ។

ដានីៈ ជាអក្សរសាស្ត្រយើងរៀនដូចថាឲ្យអាន ឲ្យសរសេរ ។

នោះៈ អានសរសេរវាគោរពតាមវចនានុក្រមហើយ អត់ទៅមានវចនានុក្រមថ្មីអត់មានទេ ប៉ុន្តែវាចេះចប់ប្រយោគកុំមុយនីស្តអត់សូវគិតពាក្យនេះប៉ុន្មានទេ គ្រាន់តែដាក់បឋមសិក្សា ពួកដែលបោះពុម្ពសៀវភៅហ្នឹងដាក់បឋមសិក្សា ដាក់អក្សរគ-ឋ មិនមែនដាក់ដ-ដណា បានខ្ញុំប្រាប់ថាអាហ្នឹងវាមិនមែនទី១ទេ គ-ឋមិនមែនទី១ទេ បឋមមិនដឹងទៅម៉េច បើដ-ដបានវាប្រែថាទី១ ។

ដានីៈ គ-ឋ មិនមែនទេ?

នោះ: មិនមែនទេ "បថ" ពាក្យយកមែនទែនជាផ្លូវទេ "បឋ" មួយទៀតបានទី១ វាខុសឆ្គង កាលនេះអត់គិតទេ ធ្វើម៉េចឲ្យគេអានកើត ដល់ពេលហ្នឹងយើងគិតគូរហើយ ។

បូលី: លោកតាមាននៅចាំអ្នកនិពន្ធសៀវភៅ អ្នកនិពន្ធអ្នកណាខ្លះ?

នោះ: និពន្ធគ្រូធិន នៅកន្លែង.. ឥឡូវមិនដឹងទីណាត់ទីណែងទៅណាទេ ពេជ្រ ជាង ក៏ស្លាប់បាត់ទៅ គ្រូធិន មិនដឹងទៅណាទេ បែកគ្នា ។

ដានី: លោកតាមានចូលរួមនិពន្ធនឹងគេអត់?

នោះ: អត់ទេ អត់បានចូលរួមនឹងគេ ព្រោះយើងពួកភូមិភាគ បើពួកមន្ទីរគេមានគ្រប់គ្រាន់ មានអ្នកភាសា មានអ្នកអន្តរជាតិគ្រប់គ្រាន់ ហើយប្រកាសតាំងពីមុនមាន ទីវ អុល អាហ្នឹងពីមុនមក ។

បូលី: តាំងពី៣ឆ្នាំ?

នោះ: ៣ឆ្នាំ ៤ឆ្នាំមកហ្នឹង ទីវ អុល សិស្សលោក កេន វ៉ាក់សាក់ ព្រះសង្ឃប្រាជ្ញខាងអក្សរសិល្ប៍ ហ្នឹងពីមុនមក សៀវភៅ ទីវ អុល នៅមានសរសេរនៅសល់រាល់ថ្ងៃហ្នឹង អាហ្នឹងយើងធ្លាប់ឃើញមក ។

បូលី: លោកតាមានដែល? លោកតាធ្លាប់សល់ដែរ?

នោះ: អត់មានជាប់អីមកទេ ខ្ញុំសង្វាតតែរឿងធម៌ ។

ដានី: ប៉ុន្តែលោកតាមានប្រសាសន៍ថានៅសល់សៀវភៅបង្រៀននៅខ្លះ?

នោះ: សៀវភៅមានតែមិនដឹងទុកណាទេ បើខំរកឃើញខ្លះ ។

ដានី: សៀវភៅលោកតាសរសេរហ្នឹងវាអាចថាសៀវភៅហ្នឹងជាប្រវត្តិមួយដែរ ជាឯកសារប្រវត្តិសាស្ត្រ?

នោះ: ហ្នឹងហើយនេះ ដែលយើងខំថតរកទីណាត់ទីណែងកុំស៊ើបការណ៍ខ្លាំងពេកប្រវត្តិសាស្ត្រហ្នឹង

បូលី: អត់ទេ ។

នោះ: ថតខ្លាំងពេក ចង់សង្កត់ចង់ចាប់ត្រង់ណាមួយ ភ្ជាត់ទៅអាងសង្កត់ មានបំណងខូចបាបហើយ កាន់សីល៦៣ឆ្នាំហើយ ។

ដានី: បាបខ្ញុំដែលលោកតា បើខ្ញុំមានគំនិតអាក្រក់ខ្ញុំបាបខ្ញុំដែរ ខ្ញុំក៏អ្នកព្រះពុទ្ធសាសនាដូចលោកតាដែរ ។

នោះ: ព្រះពុទ្ធសាសនាតែព្រះពុទ្ធសាសនាតិចតួចទេ ខ្ញុំបួស២៤ឆ្នាំ ។

ដានី: ប៉ុន្តែយើងកាន់សីល យើងបរិសុទ្ធទៅយើងអត់ខ្លាច យើងធ្វើអំពើល្អ យើងប្រព្រឹត្តិល្អ យើងអត់ខ្លាចទេ ហើយខ្ញុំក៏អីចឹងដែរ បើសិនជាខ្ញុំសួរក្នុងបំណងអាក្រក់ប្រុងធ្វើបាបអ្នកណាមួយ ។

នៅ: ហើយបើចង់ដឹងកុំមុយនីស្តមិនកុំមុយនីស្ត ឥឡូវនិយាយពីកុំមុយនីស្តមក ។

បូលី: អត់ទេ អត់ចង់សួរនាំពីកុំមុយនីស្តទេ ។

ដានី: ដូចខ្ញុំសួរហ្នឹងប្រវត្តិ ។

នៅ: ពេលយើងរៀនឡូស៊ិចហ្នឹងគេប្រាប់អស់ហើយ ទ្រឹស្តី លទ្ធិអីៗ សម្ភារៈនិយម ។

បូលី: ចង់ដឹងពីការកសាងអន្ទង់វែងទេ មិនមែនចង់ដឹងអីទេ ។

នៅ: ខ្ញុំប្រាប់ហើយប្រាប់ទៀត ខ្ញុំមិនមែនអ្នកប្រវត្តិសាស្ត្រទេ បើ ថន សួរបានច្រើនណាស់ ។

បូលី: គេចាំលោកតា ។

នៅ: ចាំច្រើនណាស់ តែលោកនៅភ្នំពេញសម្តេច នន់ ង៉ែត នៅតែនេះដែរ ។

ដានី: លោកតារឿងធម៌ រឿងអាថខ្ញុំដូចជាមិនសូវមានចំណេះដឹងអីច្រើនទេ ។

នៅ: ខុសពីធម៌មិនសូវចាំប៉ុន្មានទេ ចាំតែចាំអត់វែងឆ្ងាយទេ ចាំគ្រាន់តែដឹងថាមានរឿងអីចឹងតែមិនដែលកត់ទុកទេ ។

ដានី: ខ្ញុំបកមកចេះទាក់ទងពី ។

នៅ: ខ្ញុំឆ្នាំនេះចូលក្បែរទារប៉ែតហើយ ម៉េចកាលហ្នឹងអ៊ុនគាត់មានអីត្រូវភ្លេចណ៎ អ៊ុនគាត់ត្រូវនឹក មានអីចឹង ភ្លេចមិនទំនង តែមិនភ្លេចរហូតទេ ។

ដានី: លោកតាទំនាក់ទំនងក្នុងក្រុមគ្រួសារលោកតាកាលពីនៅក្មេង កាលពីលោកតានៅបួសដូចថាទំនាក់ទំនងក្នុងក្រុមគ្រួសារ បងប្អូន ម្តាយអីយ៉ាងម៉េចដែរ? ដូចថាល្អ ទំនាក់ទំនងគ្នាបានជិតស្និទ្ធដែរ ឬក៏មិនសូវ?

នៅ: អត់អីទេពូជអំបូរខ្ញុំ ខ្ញុំអួតបាន គ្រាន់តែកូនខ្ញុំក៏អីចឹងដែរ គ្មានដើងកាងទេ ប៉ុន្តែសុទ្ធតែកីឡា

ដានី: អីចឹងល្អយើងទាក់ទងគ្នាស្និទ្ធស្នាលល្អកល្អើនជាមួយបងប្អូន ម្តាយលោកតា ។ ចុះជំនាន់៣ឆ្នាំយ៉ាងម៉េចដែរ យើងបានទាក់ទងគ្នា?

នៅ: ជំនាន់៣ឆ្នាំធម្មតា មានអីអ្នកណាដែលគេក្មេងក្លាំងដែលខ្វះទៅ មួយទៀតដែលធ្វើការឆ្ងេងគេវ៉ៃប្រឡំរបស់យើងខ្វះដែរ សាច់ញាតិរបស់យើងដែរ ។

ដានី: អីចឹងលោកតាមានបាត់បង់សាច់ញាតិនៅក្នុងសម័យ៣ឆ្នាំ?

នៅ: សាច់ញាតិតែបងប្អូនបង្កើតអត់ទេ ត្រឹមជីដូន ត្រឹមជីទួតមាន ។

ដានីៈ ចុះក្នុងជំនាន់៣ឆ្នាំលោកតាដែលឃើញគេវ៉ៃ ឬគេចាប់ គេធ្វើទារុណកម្មផ្ទាល់ភ្នែកទេ?

នៅៈ ទម្លាប់ខ្ញុំចេះ អារឿងបួសយូរនេះគេប្រយ័ត្នណាស់ បួសតាំងពីអាណានិគមបារាំងមក ហើយជំនាន់ឥស្សរៈហ្នឹងទាហានតែងតែឡើងមក មកដាក់ក្បែរវត្ត តាមភូមិ ទម្លាប់ខ្ញុំមិនទៅមើលទេ តាំងចិត្តថាកុំឲ្យលំបាកកុហក ទម្លាប់ខ្ញុំតាំងពីណាណីមក ឯងទៅមើលដល់និយាយប្រាប់គេត្រង់ អីចឹងកុំទៅមើល ។

ដានីៈ លោកតាក្រោយ៧៩មក ពេលដែលយើងរត់មក ហើយក្រោយសមាហរណកម្មមក ដូចថាទំនាក់ទំនងជាមួយក្រុមគ្រួសារ បងប្អូន ញាតិមិត្ត ប្ដីប្រពន្ធ យើងទំនាក់ទំនងគ្នាបានជាប់លាប់ល្អនល្អើនដដែល?

នៅៈ អត់អីទេ បានបុណ្យជួយដែរតាមមើល គ្រាប់កាំភ្លើងក៏មិនត្រូវ គ្រូនក៏អត់អី តែកូនមួយត្រូវខ្ទាក់ភ្នែកម្ខាង វាលេងគ្រាប់ពេក ។

ដានីៈ ឆ្នាំណា?

នៅៈ ជំនាន់អ៊ុនតាក់ហ្នឹង ពេលចូលស្រុកវិញហ្នឹង វានៅអាយុ១៣-១៤ គ្រាប់នៅឃ្លាំងនៅស្រះឈូក វានឹករបស់ហ្នឹងអត់មានអីគ្រប់គ្រាន់ ព្រោះគេសារយកមកទុកនៅឃ្លាំង ចុះឡើងផ្ទុះត្រូវភ្នែកកូនម្ខាង ។

ដានីៈ លោកតាដូចថាយើងធ្លាប់ពិភាក្សា ឬធ្លាប់និយាយ រឿងរ៉ាវប្រវត្តិតស៊ូ ប្រវត្តិដែលលោកតារស់នៅអន្លង់វែងនេះប្រាប់ក្រុមគ្រួសារ ឬកូនចៅដែលកើតក្រោយៗ ឬសាច់ញាតិដែលនៅភូមិស្រុក លោកតាដែលនិទាន ដែលនិយាយប្រាប់?

នៅៈ ប្រាប់ហើយ ប្រាប់តាំងពីណាពីណីមក តាំងពីជំនាន់បារាំង សិក្សាអី ចាំប៉ុន្មានចេះតែនិយាយប្រាប់ហើយអត់នេះទេ ហើយពីដូនពីតាមកធ្លាប់ជាអ្នកបុណ្យ អ្នកទាន ហ្នឹងក៏ប្រាប់ដែរ ថ្ងៃមួយថាឲ្យអាកូនប្រសារវាចិញ្ចឹមមាន់ដល់ ថាអូនអញទាំងអស់អត់មានអ្នកចិញ្ចឹមមាន់មួយទេ រកអ្នកអារកមាន់គ្មានទេ ខ្ញុំប្រាប់កូនប្រសារប្រុស ។

ដានីៈ លោកតាច្រើននិយាយប្រវត្តិពីដើមមក ពីបុរុមបុរាណមក ចុះពីសម័យតស៊ូ សម័យដែលលោកតាមករស់នៅអន្លង់វែងយើងនេះ មានដែលនិយាយទេ?

នៅៈ និយាយទាំងអស់ហ្នឹង ឥឡូវចុងបង្អស់ហើយ ខ្ញុំថា គាពត ឆ្អត ។

ដានីៈ ថាយ៉ាងម៉េចទៅ លោកតាអាចរៀបរាប់កន្លែងហ្នឹងបានទេ?

នៅៈ តែមិនបានថតទេ ។ ព្រះពុទ្ធសំដែងថាការយកប្រយោជន៍ពីគ្នាឲ្យត្រាប់សត្វឃ្មុំ ដែលយកប្រយោជន៍ពីផ្កា ឃ្មុំយកប្រយោជន៍ផ្កាបានមកធ្វើទឹក ធ្វើលំអង សព្វបែបយ៉ាងទាំងអស់

រហូតមកធ្វើសំបុក តើខូចផ្កាហ្នឹងទេ? បច្ចេកទេសកសិកម្មមិនដែលនិយាយថាចង្រ្រែមកពីឃ្មុំទេ អត់ដែលមានទេ ឃ្មុំយកមកបានជាប្រយោជន៍ ហើយផ្កានៅដដែល មនុស្សយើងយកប្រយោជន៍ពីគ្នាអីចឹង ធ្វើម៉េចបានមកយើងហើយគេក៏អត់ខាត ។

ដានីៈ លោកតានៅក្នុងក្រុមគ្រួសារ ពេលទំនេរ ពេលយើងជួបជុំគ្នា ដូចលោកតាជាចាស់ទុំច្រើនណែនាំផ្តល់ដំបូន្មានដល់ញាតិមិត្ត កូនចៅជិតខាង ច្រើនយកប្រធានបទអីមកពិភាក្សា

នៅៈ អាហ្នឹងតាមរឿងជាក់ស្តែង ឥឡូវមិនបាច់និយាយអីមែនទែនទេ និយាយរឿងជាក់ល្បែងកុំលេង ធ្វើម៉េចកុំលេង បើវាទ្រាំមិនបានលេងឲ្យមានច្បាប់ ធ្វើអីក៏ដោយឲ្យមានច្បាប់ អ្នកលេងមានច្បាប់គេលេងទៅជាអ្នកមាន ធ្វើអីក៏ដោយគោរពតាមច្បាប់កុំឲ្យអត់ច្បាប់ទេ អាហ្នឹងមិននិយាយច្បាប់មែនទែន គ្រាន់តែក្រៅ ហើយបើអ្នកដែលដឹកនាំច្រើននិយាយប្រវត្តិសម្តេចជួន ណាត ។

ដានីៈ ចំពោះលោកតាផ្ទាល់ លោកតាមានរឿងអីដែលពិបាកនិយាយប្រាប់គេ ឬក៏មិនចង់និយាយប្រាប់គេ មានរឿងហ្នឹងទេ?

នៅៈ មានរឿង គេអស់មួយដែនដីគេធ្វើអីចឹង អានេះដូចគំនរឈើគរកំពស់ភ្នំហើយយើងទៅហូតក្រោមបន្ទស់វាយ៉ាប់ អាហ្នឹងលំបាកណាស់ ត្រូវតែរើទាំងអស់

ដានីៈ មានន័យថាម៉េចទៅលោកតា?

នៅៈ អាហ្នឹងរើទាំងអស់បានវាលេចអាក្រោមគេ បើរើអស់មួយគំនរធំអីចឹង ម៉េចកើត ។

ដានីៈ អីចឹងបានន័យថាលោកតាមានរឿងរ៉ាវដែលលំបាកនិយាយ ដែលមិនចង់និយាយ?

នៅៈ មានរឿងខ្លះក្រៅបង្រៀនហើយ បើកល្អ បិទមិនល្អ បិទល្អ បើកមិនល្អ បង្រៀនអស់ហើយ អានិយាយបានត្រឹមតែនិយាយ ប៉ុន្តែវា... ឥឡូវខ្ញុំលើកអាចារ្យសុខ ដែនដី និងសម្តេច ជួន ណាត ចេញវចនានុក្រមបានបោះពុម្ពហើយ អាចារ្យ សុខ ដែនដី សិស្សសម្តេច ជួន ណាត តាសុខ ដែនដី ស្តាយទាំងពីរក្បាលហ្នឹងទៅ ថាខុសច្រើនណាស់ថាអីចឹងតែម្តង អានេះសម្តេចមានយោបល់យ៉ាងម៉េច ណែ៎ សុខ ឯងមិនចេះធ្វើការ កុង្ស៊ីសេនា ធិបតី ជាតិមួយទាំងមូល គណៈកម្មការជាតិគេឯកភាពគ្នាប្រើ ហើយគេកំណត់ថាបើផ្លូវវិញគ្រាន់តែគ្រួសទេ មិនទាន់ជាផ្លូវមែនទែនទេ បើយើងមកវាអត់ គ្រួសហ្នឹងវាណាស់ហើយ ពីមុនមកមានទេ វចនានុក្រមអត់មានទេ មានដែលនៅតាមសិលាចារឹក នៅតាមសាស្ត្រាវាអត់មានអ្នកចងក្រង ឥឡូវបានប៉ុណ្ណឹងហើយគេឯកភាពគ្នាប្រើសិនទៅកាលណាយូរទៅលោកអ្នកប្រាជ្ញណាបានប៉ុណ្ណឹងជាឈ្នាន់ហើយ យើងស្រាវជ្រាវរកទៀត

ទៅ ហើយឯកភាពគ្នាក្នុងជាតិសំរេចប្រើទៅ កុំមកថាម្នាក់ឯងឲ្យផ្ដើលគេផ្ដើលឯង សុខ ឯងមិនចេះធ្វើការ បើចង់កែរៀបចំគណៈកម្មការរបស់ជាតិមកកែទៅ មកថាម្នាក់ម៉េចបាន យើងមានមេរៀនតាំងពីអីចឹងមក ដូច្នេះអីៗយើងប្រយ័ត្នណាស់ ។

ដានី: សុខ ដែលគាត់បោះវចនានុក្រមខ្មែរ-អង់គ្លេស កាលពីជំនាន់?

នៅ: មួយ ព្រាប សុខ នេះ ពាម សុខ ។

ដានី: លោកតាខ្ញុំចង់សួរលោកតាបន្តិច លោកតាស្គាល់ តាម៉ុក ច្បាស់អីចឹង បើសិនជាកូនចៅជំនាន់ក្រោយដែលកើតក្រោយៗអត់ស្គាល់ បើសិនជាគេចង់ដឹង គេសួរលោកតាទាក់ទងពីរឿង តាម៉ុក លោកតាអាចមានប្រសាសន៍ប្រាប់ទៅក្មេងៗជំនាន់ក្រោយថាម៉េច ពីបុគ្គលលក្ខណៈរបស់ តាម៉ុក?

នៅ: ប្រាប់ហើយ ឥឡូវមានថតទេ?

បូលី: ថត ។

នៅ: ចេះយកមួយទៅ បំបែកសាមគ្គីជាតិឯង បែរចំណោញឲ្យសត្រូវ បណ្ដាលហេតុជាផ្លូវ រលំពូជសាសន៍ ឬរលាយពូជសាសន៍ ហ្នឹងសុភាសិតខ្ញុំ ។

បូលី: មានន័យថាម៉េចអ៊ំ?

នៅ: យើងឈ្លោះគ្នាឯងមានចំណោញណា ចំណោញតែសត្រូវ មិនមែនចំណោញជាតិយើងទេ ច្បាំងប៉ុន្មានឆ្នាំចំណោញអ្នកណា ស្មានចំណោញខ្មែរ អ្នកណាដែលគេយកចំណោញពីខ្មែរ ។

ដានី: លោកតាពូកខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំលោកតាទៀតហើយ ។

នៅ: យើងនិយាយពីនេះពីនោះទៅ ។

ដានី: ហើយខ្ញុំអរគុណលោកតាច្រើន ដែលផ្ដល់សម្ភាសន៍ជាមួយខ្ញុំ ជិតមួយម៉ោងជាង អរគុណលោកតាច្រើន ។

ចប់